សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

# របាយការណ៍គ្រប់គ្រង និងផែនការសកម្មភាពគ្រប់គ្រង
# ទាក់ទងនឹង

# របាយការណ៍ស៊ើបអង្កេតអនុលោមភាពរបស់ CAO

# ស្តីពី

# ធនាគារ ABBANK
# វៀតណាម និងកម្ពុជា– អាស៊ីប៉ូព៉ា និងប៉ាស៊ីហ្វិក

**(គម្រោងលេខ 29745)**

ថ្ងៃទី 12 ខែមីនា ឆ្នាំ 2026

# តារាងមាតិកា


អក្សរកាត់ និងពាក្យកាត់ .......... iii
សេចក្តីសង្ខេបប្រតិបត្តិ .......... iv
I. សេចក្តីផ្តើម .......... 1
II. គម្រោង .......... 1
III. ពាក្យបណ្តឹង CAO .......... 4
IV. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះលទ្ធផលរកឃើញ និងអនុសាសន៍របស់ CAO .......... 5
V. ការពិគ្រោះយោបល់ជាមួយក្រុមហ៊ុន និងអ្នកដាក់ពាក្យបណ្តឹង .......... 13
VI. ផែនការសកម្មភាពគ្រប់គ្រង (MAP) .......... 14
VII. សេចក្តីសន្និដ្ឋាន .......... 15
ឧបសម្ព័ន្ធ ក៖ ផែនការសកម្មភាពគ្រប់គ្រង (MAP) .......... 16

## អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| ABBank | ធនាគារពាណិជ្ជកម្មសហភាគហ៊ុនអានប៊ិញ |
| CAO | ការិយាល័យទីប្រឹក្សាដោះស្រាយវិវាទ និងអនុលោមភាព |
| CES | នាយកដ្ឋានគោលនយោបាយ និងហានិភ័យបរិស្ថាន និងសង្គម |
| CSO | អង្គការសង្គមស៊ីវិល |
| E&S | បរិស្ថាន និងសង្គម |
| ESDD | ការវាយតម្លៃដោយហ្មត់ចត់លើផ្នែកបរិស្ថាន និងសង្គម |
| ESAP | ផែនការសកម្មភាពបរិស្ថាន និងសង្គម |
| ESMS | ប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម |
| ESRP | នីតិវិធីត្រួតពិនិត្យបរិស្ថាន និងសង្គម |
| EVN | អគ្គិសនីវៀតណាម |
| EVNI | អគ្គិសនីវៀតណាមអន្តរជាតិ |
| FI | អន្តរការីហិរញ្ញវត្ថុ |
| LESS | អ្នកជំនាញជាន់ខ្ពស់ផ្នែកបរិស្ថាន និងសង្គម |
| LS2 | ស្ថានីយវារីអគ្គិសនីសេសានក្រោម 2 នៅកម្ពុជា |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| MAP | ផែនការសកម្មភាពគ្រប់គ្រង |
| MIGA | ទីភ្នាក់ងារធានាវិនិយោគពហុភាគី |
| PS | បទដ្ឋានប្រតិបត្តិរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (ឆ្នាំ 2012) |
| PSBC | ធនាគារប្រៃសណីយ៍ចិន |
| SME | សហគ្រាសខ្នាតតូច និងមធ្យម |
| US$ | ដុល្លារអាមេរិក |
| ធនាគារ Vietinbank | ធនាគារពាណិជ្ជសហភាគហ៊ុនវៀតណាមសម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្ម |
| VND | ដុងវៀតណាម |

# សេចក្តីសង្ខេបប្រតិបត្តិ

I. នៅខែធ្នូ ឆ្នាំ 2010 សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានចូលរួមវិនិយោគភាគហ៊ុននៅក្នុងធនាគារពាណិជ្ជកម្មសហភាគហ៊ុនអានប៊ិញ (ABBank) ក្នុងប្រទេសវៀតណាម ក្នុងតម្លៃប្រមាណ US$40.6 លាន តាមរយៈ ប័ណ្ណបំណុលអាចបម្លែងជាភាគហ៊ុនដោយបង្ខំ (គម្រោង)។ គោលបំណងនៃការវិនិយោគនេះគឺដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ បង្កើតការងារ និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសវៀតណាម។ នៅក្នុងខែឧសភា ឆ្នាំ 2024 សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) បានបញ្ចប់ការដកទុកវិនិយោគដែលបានគ្រោងទុកពីភាគហ៊ុន របស់ខ្លួននៅក្នុងធនាគារ ABBank។

II. ចន្លោះឆ្នាំ 2018 និង 2024 ការិយាល័យទីប្រឹក្សាដោះស្រាយវិវាទ និងអនុលោមភាព (CAO) បានទទួលពាក្យបណ្តឹងជាច្រើនករណីពីសហគមន៍ដែលរងផលប៉ះពាល់ដោយស្ថានីយវារីអគ្គិសនីសេសានក្រោម 2 នៅកម្ពុជា (LS2) ដែលតំណាងដោយសំណាក់អង្គការសង្គមស៊ីវិល (CSOs)។[1] ពាក្យបណ្តឹងបានចោទថា IFC រងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុពី LS2 តាមរយៈអតិថិជនអន្តរការីហិរញ្ញវត្ថុ (FI) ចំនួនបីរបស់ខ្លួនគឺធនាគារ ABBank ធនាគារ Vietinbank និង ធនាគារប្រៃសណីយ៍ចិន (PSBC)។ CAO បានបិទសំណុំរឿងដែលចោទប្រកាន់ពីការលាតត្រដាងតាមរយៈធនាគារ PSBC និង Vietinbank ដោយបញ្ជាក់ថាមានភស្តុតាងមិនគ្រប់គ្រាន់នៃទំនាក់ទំនងហិរញ្ញវត្ថុ។[2]

III. ទោះបីជា CAO បានបញ្ជាក់ថាមិនមានទំនាក់ទំនងហិរញ្ញវត្ថុរវាង IFC និង LS2 ក៏ដោយ CAO បានបន្តស៊ើបអង្កេតពាក្យបណ្តឹងទាក់ទងនឹងការវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុងធនាគារ ABBank។ មុនពេលការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ក្នុងឆ្នាំ 2010 ធនាគារ ABBank បានវិនិយោគនៅក្នុងក្រុមហ៊ុនអគ្គិសនីវៀតណាមអន្តរជាតិ (EVNI)។ មុនពេលការ វិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ក្រុមហ៊ុន EVNI បានផ្តល់ហិរញ្ញប្បទានដល់ការសិក្សាលទ្ធភាពដំបូងសម្រាប់ការអភិវឌ្ឍរោងចក្រវារីអគ្គិសនី LS2។ គ្មានប្រាក់ចំណូលពីការវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុងធនាគារ ABBank ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុន EVNI ឬការវិនិយោគរបស់ក្រុមហ៊ុន EVNI នៅក្នុង LS2 នោះទេ។ មិនមានទំនាក់ទំនងហិរញ្ញវត្ថុដោយផ្ទាល់ ឬដោយប្រយោលរវាង IFC និង EVNI ឬរវាង IFC និង LS2 ទេ។

IV. CAO បានកំណត់កំហុសមួយនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ឆ្នាំ 2010 រវាង IFC និង ABBank ដែលអនុញ្ញាតឱ្យ CAO ផ្សារភ្ជាប់ IFC ជាមួយនឹង LS2។ កិច្ចព្រមព្រៀងដែលត្រូវបានតាក់តែងឡើងក្នុងន័យទូលំទូលាយនេះ ត្រូវបានបកស្រាយថា តម្រូវឱ្យធនាគារ ABBank អនុវត្តគោលនយោបាយបរិស្ថាន និងសង្គម (E&S) របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ប្រកប ដោយអនុភាពប្រតិសកម្មទៅលើផលប័ត្រដែលមានស្រាប់របស់ខ្លួន តាំងពីមុនពេលមានការវិនិយោគពី IFC ទៅទៀត។ ការតាក់តែងកិច្ចព្រមព្រៀងដែលមានកំហុសនេះ មិនបានឆ្លុះបញ្ចាំងពីបំណងរបស់ភាគីនានា ឬគោលនយោបាយ E&S របស់ IFC ទេ។

V. ទោះជាយ៉ាងណាក៏ដោយ ទាំងគោលនយោបាយនិរន្តរភាពឆ្នាំ 2006 និងនីតិវិធីពិនិត្យ E&S (ESRP) ដែលមានជាធរមាននៅពេលវាយតម្លៃគម្រោង មិនតម្រូវឱ្យមានការអនុវត្ត លក្ខខណ្ឌតម្រូវ E&S របស់ IFC ទៅលើផលប័ត្រនៃ FI ដែលមានអត្ថិភាពមុនពេលការវិនិយោគរបស់ IFC នោះទេ។ ទោះបីជាគោលនយោបាយនិរន្តរភាព IFC ឆ្នាំ 2006 ដែលអាចអនុវត្តនៅពេលនោះ

មិនមានបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះក៏ដោយ ក៏ការធ្វើបច្ចុប្បន្នភាពឆ្នាំ 2012 នៃក្របខ័ណ្ឌនិរន្តរភាព IFC ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល IFC បានបញ្ជាក់យ៉ាងច្បាស់អំពីចំណុចនេះដែរ។ កថាខណ្ឌទី 37 ចែងថា នៅពេលដែល IFC ផ្តល់ការគាំទ្រផ្នែកភាគហ៊ុន ឬហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ លក្ខខណ្ឌតម្រូវខាង E&S របស់ IFC អនុវត្តតែចំពោះផលប័ត្ររបស់អតិថិជន FI ក្រោយពេលដែល IFC ក្លាយជាភាគទុនិក ឬវិនិយោគិនប៉ុណ្ណោះ។

VI. ដូច្នេះ លទ្ធផលរកឃើញរបស់ CAO មិនស្របនឹងលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពឆ្នាំ 2006 ឬការធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់នៃក្របខ័ណ្ឌនិរន្តរភាព IFC ឆ្នាំ 2012 នោះទេ។ ការអនុវត្តលក្ខខណ្ឌតម្រូវខាង E&S របស់ IFC ប្រកបដោយអនុភាពប្រតិសកម្មទៅលើផលប័ត្រដែលមានស្រាប់របស់អតិថិជន FI មុនពេលការវិនិយោគរបស់ IFC

---

[1] ការរៀបចំគម្រោង LS2 បានចាប់ផ្តើមនៅឆ្នាំ 2007។ នៅឆ្នាំ 2012 ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបកម្ពុជា និងក្រុមហ៊ុនវារីអគ្គិសនីឡានឆាងរបស់ប្រទេសចិន

ក្រុមហ៊ុន International Energy បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដើម្បីអភិវឌ្ឍគម្រោង LS2។ ការសាងសង់ទំនប់បានចាប់ផ្តើមនៅឆ្នាំ 2013 ហើយ
ស្ថានីយវារីអគ្គិសនីនេះបានចាប់ផ្តើមដាក់ឲ្យដំណើរការនៅឆ្នាំ 2018។

[2] សូមមើលករណី CAO ស្តីពី PSBC 2 និង Vietinbank នៅលើគេហទំព័រhttps://www.cao-ombudsman.org/cases/cambodia-psbc-02,

មិនមែនជាបំណងទុកជាមុន ហើយក៏មិនអាចទៅរួច ឬស្របទៅតាមការអនុវត្តជា សកល ឬគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍ពហុភាគី (MDBs) ដទៃទៀតនោះដែរ។ វាក៏នឹងនាំឱ្យមានស្ថានភាពមិនអាចអនុវត្តទៅបានផងដែរ ប្រសិនបើគោលនយោបាយរបស់ IFC ត្រូវយកមកអនុវត្តចំពោះផលប័ត្រ ដែល IFC មិនបានផ្តល់ថវិកា និងមិនអាចមានឥទ្ធិពលលើបាន។ គោលការណ៍ទូទៅដែលត្រូវបានអនុវត្តក្នុងការប្រើប្រាស់គោលនយោបាយរបស់ IFC គឺថា គោលនយោបាយទាំងនោះវែងឆ្ងាយ ហើយត្រូវបានយកមកអនុវត្តចំពោះការវិនិយោគរបស់ IFC នៅពេលដែលការវិនិយោគនោះត្រូវបានបង្កើតឡើង។

VII. សរុបមក ទាំងគម្រោងវារីអគ្គិសនី LS2 ដែលជាទីតាំងកើតមានការខូចខាតដូចដែលបានចោទប្រកាន់ និងទាំងក្រុមហ៊ុន EVNI មិនត្រូវបានតម្រូវឱ្យអនុវត្តគោលការណ៍ E&S របស់ IFC នោះទេ ដោយសារពួកគេមិនបានទទួលហិរញ្ញប្បទានពី IFC។ ដូច្នេះ IFC មិនអាចផ្តល់ជូននូវសកម្មភាពជាក់លាក់ណាមួយសម្រាប់គម្រោងនៅក្នុងផែនការសកម្មភាពគ្រប់គ្រង (MAP) បានទេ។

VIII. IFC វាយតម្លៃខ្ពស់ចំពោះអនុសាសន៍ជាប្រព័ន្ធរបស់ CAO ដើម្បីពង្រឹងការអនុវត្តរបស់ IFC បន្ថែមទៀតលើការគ្រប់គ្រងហានិភ័យ E&S នៅក្នុងការវិនិយោគរបស់ខ្លួនលើ FIs។ អនុសាសន៍ទាំងនេះគឺស្របគ្នាជាមួយ និងឆ្លុះបញ្ចាំងពីការកែលម្អនានា ដែល IFC បានអនុវត្តរួចមកហើយតាំងពីឆ្នាំ 2010។

IX. នៅក្នុងផែនការ MAP, IFC កំណត់សកម្មភាពដើម្បីពង្រឹងបន្ថែមទៀត នូវការណែនាំសម្រាប់បុគ្គលិករបស់ IFC លើការគ្រប់គ្រងហានិភ័យ E&S ក្នុងការវិនិយោគលើ FI។

## I. សេចក្តីផ្តើម

1. របាយការណ៍គ្រប់គ្រងនេះឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ការិយាល័យទីប្រឹក្សាដោះស្រាយ វិវាទ និងអនុលោមភាព (CAO) លើពាក្យបណ្តឹងមួយក្នុងឆ្នាំ 2018 ដែលបានអះអាងថា ការវិនិយោគភាគហ៊ុនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) នៅក្នុងធនាគារពាណិជ្ជសហភាគហ៊ុនអានប៊ិញ (ABBank ឬគម្រោង) នៅប្រទេសវៀតណាមអាចទាក់ទងនឹងផលប៉ះពាល់បរិស្ថាន និងសង្គម (E&S) ពីស្ថានីយវារីអគ្គិសនីមួយកន្លែងនៅក្នុងប្រទេសកម្ពុជា។

2. ធនាគារ ABBank ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1993 នៅភាគខាងត្បូងប្រទេសវៀតណាម ដែលជាធនាគារឯកជនខ្នាតមធ្យម។ វាដំណើរការបណ្តាញប្រតិបត្តិការចំនួន 165 ទីតាំងនៅទូទាំង 34 ខេត្ត និងក្រុងទូទាំងប្រទេស ដោយផ្តល់ជូននូវសេវាកម្មធនាគារពេញលេញ ដោយផ្តោតលើសហគ្រាសធុនតូច និងមធ្យម (SME) និងអតិថិជនជាអាជីវករលក់រាយ។ ភាគទុនិកធំជាងគេបច្ចុប្បន្នរបស់ធនាគារ ABBank រួមមានក្រុមហ៊ុន Hanoi General Export Import Corporation និងធនាគារ Malayan Banking Berhad។ ក្រុមហ៊ុនអគ្គិសនីវៀតណាម(EVN) គឺជាភាគទុនិកនៅក្នុងធនាគារ ABBank រហូតដល់ឆ្នាំ 2016 នៅពេលដែល EVN បានដកទុនវិយោគទាំងស្រុង ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល សម្រាប់សហគ្រាសរដ្ឋក្នុងការដកទុនវិយោគពីហ៊ុនកាន់កាប់ដែលមិនមែនជាស្នូល។

3. របាយការណ៍គ្រប់គ្រងត្រូវបានរៀបចំជាប្រាំពីរផ្នែក។ ផ្នែកទី I គឺជាសេចក្តីផ្តើមនេះ។ ផ្នែកទី II ពិពណ៌នាអំពីគម្រោង។ ផ្នែកទី III ពិពណ៌នាអំពីករណីពាក្យបណ្តឹង CAO។ ផ្នែកទី IV គូសបញ្ជាក់ពីការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រង IFC ចំពោះលទ្ធផលរកឃើញ និងអនុសាសន៍នៃការស៊ើបអង្កេតអនុលោមភាពរបស់ CAO។ ផ្នែកទី V ពិភាក្សាអំពីការពិគ្រោះយោបល់ជាមួយធនាគារ ABBank ហើយនិងអ្នកដាក់ពាក្យបណ្តឹង និងផ្នែកទី VI ពន្យល់អំពីផែនការសកម្មភាពគ្រប់គ្រង (MAP)។ ផ្នែកទី VII ផ្តល់នូវសេចក្តីសន្និដ្ឋាន។ ឧបសម្ព័ន្ធ ក មានផែនការ MAP ជាទម្រង់តារាង។

## II. គម្រោង

4. នៅថ្ងៃទី 28 ខែធ្នូ ឆ្នាំ 2010, IFC បានជាវ ប័ណ្ណបំណុលអាចបម្លែងជាភាគហ៊ុន ដែលចេញដោយធនាគារ ABBank។ គម្រោង (#29745) ពាក់ព័ន្ធនឹងការវិនិយោគភាគហ៊ុនរបស់ IFC ចំនួន US$40.6 លាន (VND 792 ពាន់លាន)[3] ក្នុងទម្រង់ជាប័ណ្ណបំណុលអាចបម្លែងជាភាគហ៊ុនដោយបង្ខំ។ គោលបំណងនៃការវិនិយោគនេះគឺដើម្បីបង្កើនបរិយាបន្នហិរញ្ញវត្ថុ បង្កើត ការងារ និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសវៀតណាម។ នៅក្នុងខែមេសា ឆ្នាំ 2013 IFC បានប្តូរ ប័ណ្ណបំណុល ទៅជាភាគហ៊ុន ហើយជាលទ្ធផល បានក្លាយជាភាគទុនិក ដែលកាន់កាប់ភាគហ៊ុនធម្មតាចំនួន 10 ភាគរយរបស់ធនាគារ ABBank។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីបានសម្រេចចិត្តមិនចូលរួមក្នុងការបោះផ្សាយសិទ្ធិទិញភាគហ៊ុនរបស់ធនាគារ ABBank កាលពីខែធ្នូ ឆ្នាំ 2021 ចំណែកភាគហ៊ុនរបស់ IFC ត្រូវបានកាត់បន្ថយមកត្រឹម 8.2 ភាគរយ។ នៅក្នុងខែឧសភា ឆ្នាំ 2024, IFC បានដកចេញទាំងស្រុងនូវ ភាគហ៊ុនរបស់ខ្លួនតាមរយៈការលក់ចេញនៅលើទីផ្សារ ដោយអនុលោមតាម គោលការណ៍នៃការដកចេញប្រកបដោយការទទួលខុសត្រូវ។

5. ក្នុងអំឡុងពេលមានទំនាក់ទំនងជាមួយធនាគារ ABBank, IFC ក៏បានចូលរួម ជាមួយធនាគារនេះផងដែរនៅក្នុងគំនិតផ្តួចផ្តើមផ្នែកហិរញ្ញវត្ថុ និង មិនមែនហិរញ្ញវត្ថុផ្សេងទៀត។ ការវិនិយោគដំបូងរបស់ IFC នៅក្នុងធនាគារ ABBank គឺជាកម្ចីសម្រាប់ពាណិជ្ជកម្មចំនួន

US$18 លាន ដែលត្រូវបានផ្តល់ឱ្យនៅក្នុងខែមេសា ឆ្នាំ 2009 ក្រោមកម្មវិធីធានាហិរញ្ញប្បទានពាណិជ្ជកម្មសកលរបស់ IFC ដែលនៅតែមានសុពលភាពនៅឡើយ (#27851)។ នៅក្នុងឆ្នាំ 2017, IFC រួមជាមួយអ្នកផ្តល់កម្ចីស្របគ្នាដទៃទៀត បានផ្តល់ប្រាក់កម្ចី ចំនួន US$150 លាន (#40081) ដោយក្នុងនោះទំហំកម្ចីសុទ្ធរបស់ IFC មានចំនួន US$28.5 លាន ដើម្បីគាំទ្រដល់ការផ្តល់កម្ចីរបស់ធនាគារ ABBank ដល់សហគ្រាសធុនតូចបំផុត SMEs ដែលមានស្ត្រីជាម្ចាស់នៅក្នុងប្រទេសវៀតណាម។ ចន្លោះឆ្នាំ 2010 និង 2021, IFC បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសេវាកម្មប្រឹក្សាយោបល់ចំនួនប្រាំមួយជាមួយធនាគារ ABBank ដោយផ្តោតលើវិស័យដូចជា ហិរញ្ញប្បទានសម្រាប់ SME ហិរញ្ញប្បទានសម្រាប់

---

3 កញ្ចប់ថវិកាចំនួន US$49 លាន ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ IFC នៅក្នុងខែវិច្ឆិកា ឆ្នាំ 2010 ដែលក្នុងនោះថវិកាចំនួន US$40.6 លាន ត្រូវបានផ្តល់ការសន្យាខ្ចី និងបានបើកផ្តល់រួចរាល់។

ហិរញ្ញប្បទាន និងអភិបាលកិច្ចសាជីវកម្ម ដើម្បីជួយធនាគារ ABBank ឱ្យ អភិវឌ្ឍខ្លួនទៅជាធនាគារឯកទេសបម្រើសេវាកម្មដល់ SMEs—ដែលជាផ្នែកមួយនៃសេដ្ឋកិច្ចវៀតណាមដែលមិនទាន់ទទួលបានសេវាបំពេញតាមតម្រូវការនៅឡើយ។

6. គម្រោងនេះស្របនឹងយុទ្ធសាស្ត្រ 2010-2012 របស់ IFC សម្រាប់ប្រទេសវៀតណាម ដែលមានគោលបំណងបង្កើនភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចរបស់ប្រទេសក្នុងអំឡុងពេលផ្លាស់ប្តូរ របស់ខ្លួនទៅជាសេដ្ឋកិច្ចទីផ្សារ និងលើកកម្ពស់កំណើនប្រកបដោយបរិយាបន្ន។ IFC បានខិតខំសម្រេចបាននូវគោលដៅនេះតាមរយៈការវិនិយោគ និងការគាំទ្រផ្នែកប្រឹក្សាយោបល់ក្នុងវិស័យហិរញ្ញវត្ថុ SME ក៏ដូចជាការពង្រឹងអភិបាលកិច្ចសាជីវកម្មសម្រាប់សហគ្រិនមូលដ្ឋាន។ គម្រោងនេះបានផ្តល់ឱកាសដ៏វិសេសវិសាលមួយសម្រាប់ IFC ក្នុងការជំរុញបេសកកម្មបរិយាបន្នហិរញ្ញវត្ថុ និងការកាត់បន្ថយភាពក្រីក្ររបស់ខ្លួនតាមរយៈការឈានទៅដល់ SMEs ដែលមិនទាន់ទទួលបានសេវាគ្រប់គ្រាន់នៅក្នុងតំបន់ដាច់ស្រយាល និង ការគាំទ្រដល់កំណើនរបស់ធនាគារ ABBank តាមរយៈផលិតផល និងបណ្តាញចែកចាយថ្មីៗ។ បន្ថែមពីនេះ គម្រោងនេះមានគោលបំណងលើកកម្ពស់ការអនុវត្តល្អបំផុតនៃអភិបាលកិច្ចសាជីវកម្ម និង រួមចំណែកដល់ការអភិវឌ្ឍទីផ្សារមូលធនរបស់ប្រទេសវៀតណាម។

7. គម្រោងនេះត្រូវបានវាយតម្លៃក្រោមគោលនយោបាយនិរន្តរភាពឆ្នាំ 2006 ហើយត្រូវបានចាត់ថ្នាក់ជាអន្តរការីហិរញ្ញវត្ថុ (FI) ស្របតាមគោលនយោបាយនោះ។ យោងតាមគោលនយោបាយនេះ ធនាគារ ABBank តម្រូវឱ្យ៖ (i) អនុវត្តបញ្ជីដកចេញរបស់ IFC (ii) អនុលោមតាមច្បាប់ជាតិ ក្នុងករណីដែលសកម្មភាពហិរញ្ញប្បទានមានហានិភ័យសង្គម ឬបរិស្ថានកម្រិតទាប និង (iii) អនុវត្តបទដ្ឋានប្រតិបត្តិ (PS) របស់ IFC ក្នុងករណីដែលសកម្មភាពហិរញ្ញប្បទានមានហានិភ័យសង្គម ឬបរិស្ថានកម្រិតខ្ពស់។ គោលនយោបាយនេះក៏តម្រូវឱ្យ FI បង្កើត និងថែរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) ដើម្បីឱ្យការវិនិយោគរបស់ខ្លួនបំពេញតាមលក្ខខណ្ឌតម្រូវនៃគោលនយោបាយរបស់ IFC។ IFC នឹងត្រួតពិនិត្យការអនុវត្តរបស់ FI ដោយផ្អែកលើការអនុវត្ត ESMS របស់ FI។ ទាំងគោលនយោបាយ និងនីតិវិធីពិនិត្យ E&S (ESRP) ដែលមានជាធរមាននៅពេលវាយតម្លៃគម្រោង មិនតម្រូវ ឱ្យមានការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ទៅលើផលប័ត្ររបស់ FI ដែលមានមុនពេលការ វិនិយោគរបស់ IFC នោះទេ។

8. ក្នុងអំឡុងពេលវិនិយោគភាគហ៊ុនរបស់ IFC, IFC បានត្រួតពិនិត្យជាប្រចាំនូវការអនុវត្ត E&S របស់ធនាគារ ABBank។ ការត្រួតពិនិត្យនេះរួមមានការពិនិត្យឡើងវិញ នូវរបាយការណ៍ស្តីពីការអនុវត្ត E&S ប្រចាំឆ្នាំរបស់ធនាគារ ABBank ពីឆ្នាំ 2012 ដល់ឆ្នាំ 2023 និងរួមបញ្ចូលទាំងការចុះពិនិត្យផ្ទាល់ ក៏ដូចជាការចុះទៅត្រួតពិនិត្យទីតាំងជាក់ស្តែង (SSV) សរុបចំនួនប្រាំបួនលើកនៅធនាគារ ABBank ពីឆ្នាំ 2012 ដល់ឆ្នាំ 2024។

9. ក្នុងចំណោមសកម្មភាពត្រួតពិនិត្យទាំងនេះរបស់ខ្លួន IFC បានពិនិត្យឡើងវិញនូវការអនុវត្តរបស់ ABBank ក្នុងការអនុវត្តផែនការប្រព័ន្ធគ្រប់គ្រងសង្គម និងបរិស្ថាន (SEMS) (ឥឡូវស្គាល់ថាជាផែនការសកម្មភាពបរិស្ថាន និងសង្គម ESAP) ស្របតាមលក្ខខណ្ឌតម្រូវ នៃគោលនយោបាយដែលមានជាធរមាននៅពេលនោះ។[4] ធាតុ ESAP មួយបានផ្តល់មិនត្រឹមត្រូវសម្រាប់ការអនុវត្តលក្ខខណ្ឌតម្រូវ E&S កាន់តែទូលំទូលាយចំពោះផលប័ត្រដែលមានស្រាប់មុនពេលការវិនិយោគរបស់ IFC។ ទោះជាយ៉ាងណាក៏ដោយ ធាតុនេះមិនត្រូវបានត្រួតពិនិត្យទេ ពីព្រោះវាផ្ទុយនឹងការអនុវត្តដែលមានស្រាប់ ហើយមិនត្រូវបានទាមទារដោយគោលនយោបាយនិរន្តរភាពឆ្នាំ 2006 នោះទេ។

10. IFC បានផ្តល់ការគាំទ្រដល់ធនាគារ ABBank ដើម្បីពង្រឹងសមត្ថភាព ESMS និង E&S ផ្ទៃក្នុងរបស់ខ្លួន។ ទោះបីជាធនាគារ ABBank បានធ្វើការកែលម្អមួយចំនួនទាំងនេះក៏ដោយ ក៏វានៅតែខ្វះនីតិវិធី E&S ត្រឹមត្រូវ និងសមត្ថភាពក្នុងការអនុវត្ត PSs ប្រកបដោយ ប្រសិទ្ធភាព ទៅលើផលប័ត្ររងដែលមានប្រភពចេញពីការវិនិយោគភាគហ៊ុនរបស់ IFC។ ជាលទ្ធផល ការវាយតម្លៃលើការអនុវត្ត E&S របស់ធនាគារ ABBank ត្រូវបានវាយតម្លៃថាមិនទាន់ពេញចិត្តខ្លះ ហើយការវាយតម្លៃនេះនៅតែរក្សាដដែលរហូតមកដល់ពេលដែល IFC បានដកការវិនិយោគចេញទាំងស្រុងនៅក្នុងឆ្នាំ 2024។ ខណៈពេលដែលចំណុចខ្វះខាតមួយចំនួននៅក្នុងការអនុវត្តលក្ខខណ្ឌតម្រូវ E&S ស្របតាមគោលនយោបាយមានពេញមួយរយៈពេលនៃការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ចំណុចខ្វះខាតទាំងនេះមិនមានផលប៉ះពាល់ដល់ការវិនិយោគរបស់ធនាគារ ABBank នៅក្នុងក្រុមហ៊ុនអគ្គិសនីវៀតណាមអន្តរជាតិ (EVNI) ឬការវិនិយោគរបស់ក្រុមហ៊ុន EVNI នៅក្នុងគម្រោងវារីអគ្គិសនីសេសានក្រោម 2 (LS2)

---

4 នៅពេលវិនិយោគនៅឆ្នាំ 2010, ESAP ត្រូវបានគេហៅថាផែនការ SEMS។ របាយការណ៍នេះប្រើពាក្យ ESAP ដើម្បីឲ្យស្របទៅនឹងលក្ខខណ្ឌតម្រូវ និងការអនុវត្ត E&S បច្ចុប្បន្ន។

ដែលបានកើតឡើងតាំងពីមុនការចូលរួមរបស់ IFC ជាមួយធនាគារ ABBank ដែលត្រូវបានលើកឡើងនៅក្នុងពាក្យបណ្ដឹង CAO (សូមមើលផ្នែកទី III ខាងក្រោម)។

**ក. ទំនាក់ទំនងជាមួយក្រុមហ៊ុន EVNI**

11. ក្រុមហ៊ុន EVNI គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន EVN ដែលជាសហគ្រាសរដ្ឋធំមួយរបស់វៀតណាម ដែលមានជំនាញខាងការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី។ នៅក្នុងខែឧសភា ឆ្នាំ 2007 ក្រុមហ៊ុន EVN និងដៃគូចំនួន 17 ទៀត រួមទាំងធនាគារ ABBank ផងដែរ បានជំរុញឱ្យមានការបង្កើតក្រុមហ៊ុន EVN Cambodia Joint Stock Company ដែលក្រោយមកត្រូវបានប្ដូរឈ្មោះទៅជា EVNI នៅក្នុងឆ្នាំ 2008។

12. ក្រុមហ៊ុន EVNI ធ្វើប្រតិបត្តិការនៅប្រទេសវៀតណាម ឡាវ និងកម្ពុជា ដែលអាជីវកម្មសំខាន់ៗរបស់ខ្លួនគឺវិនិយោគ ការគ្រប់គ្រងគម្រោង និងការប្រឹក្សាយោបល់ត្រួតពិនិត្យសម្រាប់ការសាងសង់គម្រោងថាមពល។ ធនាគារ ABBank បានទិញភាគហ៊ុនក្រុមហ៊ុន EVNI ចំនួន 6 ភាគរយក្នុងឆ្នាំ 2007 ហើយបានបង្កើនភាគហ៊ុនរបស់ខ្លួនដល់ 10.31 ភាគរយនៅថ្ងៃទី 1 ខែវិច្ឆិកា ឆ្នាំ 2010។ ការវិនិយោគទាំងនេះមានមុនការវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុងធនាគារ ABBank។ ធនាគារ ABBank មិនបានផ្ដល់ថវិកាបន្ថែមណាមួយដល់ក្រុមហ៊ុន EVNI ទៀតនោះទេ ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាវភាគហ៊ុនជាមួយ IFC ក្នុងខែធ្នូ ឆ្នាំ 2010។ ដូច្នេះ ប្រាក់ចំណូលពីការវិនិយោគរបស់ IFC ក្នុង ABBank មិនត្រូវបានប្រើសម្រាប់ផ្ដល់ហិរញ្ញប្បទានដល់ EVNI ឬការវិនិយោគរបស់ EVNI ក្នុង LS2 ឡើយ។ ដោយសារហេតុផលដូចគ្នានេះ EVNI មិនត្រូវបានទទួលរងនូវការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC នោះទេ។

**ខ. ទំនាក់ទំនងជាមួយ LS2**

13. LS2 គឺជារោងចក្រវារីអគ្គិសនីធំជាងគេរបស់ប្រទេសកម្ពុជា — ទំនប់វារីអគ្គិសនី 400 មេហ្គាវ៉ាត់ ដែលមានទីតាំងនៅក្នុងស្រុកសេសាន លើទន្លេសេសាន ចម្ងាយប្រហែល 25 គីឡូម៉ែត្រពីលើទន្លេមេគង្គ។[5]

14. ការសិក្សាស្រាវជ្រាវសម្រាប់គម្រោង LS2 បានចាប់ផ្ដើមនៅក្នុងឆ្នាំ 2007 នៅពេលដែលក្រសួងរ៉ែ និងថាមពលរបស់កម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រុមហ៊ុន EVNI ដើម្បីអនុវត្តការសិក្សាលទ្ធភាពសម្រាប់គម្រោងនេះ។

15. ចន្លោះឆ្នាំ 2007 និង 2010 ក្រុមហ៊ុន EVNI បានធ្វើការសិក្សាលទ្ធភាព និងរៀបចំផែនការគម្រោង ព្រមទាំងបានរៀបចំឯកសារបច្ចេកទេសផងដែរ។ ការវាយតម្លៃផលប៉ះពាល់បរិស្ថានត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2008 ហើយត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជាក្នុងខែមិថុនា ឆ្នាំ 2010។ នៅឆ្នាំ 2011 ក្រុមហ៊ុន EVNI បានបញ្ចប់គោលនយោបាយសំណង និងការតាំងទីលំនៅថ្មីសម្រាប់គម្រោង LS2។

16. រដ្ឋាភិបាលកម្ពុជា ឬក្រុមហ៊ុន EVNI មិនត្រូវបានតម្រូវឱ្យអនុវត្តការសិក្សាដែលបានរៀបរាប់ខាងលើ ឱ្យស្របតាមបទដ្ឋានប្រតិបត្តិរបស់ IFC (IFC PSs) នៅពេលណាមួយឡើយ ដោយសារការសិក្សាទាំងនេះត្រូវបានបញ្ចប់រួចរាល់មុនពេលដែល IFC បានចូលរួមវិនិយោគលើភាគហ៊ុននៅក្នុងធនាគារ ABBank។ ដូច្នេះ រដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន EVNI មិនត្រូវបានតម្រូវឲ្យគោរពតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC ឡើយ។

17. ក្នុងអំឡុងឆ្នាំ 2007-2011 ក្រុមហ៊ុន EVNI គឺជាម្ចាស់ភាគហ៊ុនភាគច្រើននៃគម្រោង LS2។ ការចំណាយរបស់ក្រុមហ៊ុន EVNI ដែលបានកើតឡើងក្នុងអំឡុងពេលនៃការសិក្សាស្រាវជ្រាវនេះ មានចំនួនប្រហែល US$9.3 លាន (VND 231 ពាន់លាន)។

18. នៅក្នុងឆ្នាំ 2011 រដ្ឋាភិបាលកម្ពុជាបានអនុម័តលើការអភិវឌ្ឍគម្រោង LS2 ដោយក្នុងនោះ ដំបូងឡើយក្រុមហ៊ុន EVNI កាន់កាប់ភាគហ៊ុន 51 ភាគរយ និងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប របស់ប្រទេសកម្ពុជាកាន់កាប់ភាគហ៊ុន 49 ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីឆ្នាំ 2011 ក្រុមហ៊ុន EVNI មិនបានរួមចំណែកដើមទុនបន្ថែមសម្រាប់ការអភិវឌ្ឍ LS2 ទេ។[6]

---

[5] ព័ត៌មានអំពីអនុគម្រោងនៃអនុគម្រោងត្រូវបានដកស្រង់ចេញពីប្រភពដែលមានជាសាធារណៈ ឬ របាយការណ៍ស៊ើបអង្កេតរបស់ CAO។ IFC មិនដែលមានទំនាក់ទំនងអ្វីជាមួយអនុគម្រោងនៃអនុគម្រោង និង ប្រតិបត្តិកររបស់អនុគម្រោងនេះទេ។

[6] EVNI របាយការណ៍ប្រចាំឆ្នាំ 2011https://static2.vietstock.vn/data/OTC/2011/BCTN/VN/EVNI_BCTN_2011.pdf

19. នៅឆ្នាំ 2012 ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបនៃប្រទេសកម្ពុជា និងក្រុមហ៊ុន Hydrolancang International Energy របស់ប្រទេសចិន ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន China Huaneng Group បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដើម្បីអភិវឌ្ឍគម្រោងនេះ។ ក្រុមហ៊ុន China Huaneng Group គឺជាក្រុមហ៊ុនផលិតអគ្គិសនីដ៏ធំរបស់រដ្ឋចិន។ ក្រុមហ៊ុន EVNI បានរក្សាទុកភាគហ៊ុនចំនួន 10 ភាគរយ នៅក្នុងគម្រោងនេះ ដែលផ្តល់ដោយសមាគមក្រុមហ៊ុនថ្មី ដើម្បីជាការប៉ះប៉ូវដល់ក្រុមហ៊ុន EVNI សម្រាប់ការចំណាយនានាក្នុងអំឡុងដំណាក់កាលស្វែងយល់។[7]

20. ការសាងសង់ទំនប់ LS2 បានចាប់ផ្តើមនៅឆ្នាំ 2013។ ការតាំងទីលំនៅថ្មីបានកើតឡើងនៅឆ្នាំ 2015-2016។ អាងស្តុកទឹកនេះត្រូវបានបំពេញនៅឆ្នាំ 2017 ហើយការសាងសង់ត្រូវបានបញ្ចប់នៅឆ្នាំ 2018។ ក្រុមហ៊ុន EVNI មិនបានចូលរួមចំណែកផ្នែកហិរញ្ញវត្ថុ ឬប្រតិបត្តិការក្នុងការសាងសង់ទំនប់នេះទេ។

21. LS2 បានដាក់ឲ្យដំណើរការនៅឆ្នាំ 2018 ហើយចាប់តាំងពីពេលនោះមកត្រូវបានគ្រប់គ្រង និងដំណើរការដោយក្រុមហ៊ុន Hydropower LS2 ដែលជាក្រុមហ៊ុនវិនិយោគរួមគ្នារវាងក្រុមហ៊ុន Hydrolancang International Energy និងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបនៃប្រទេសកម្ពុជា។ ក្រុមហ៊ុន EVNI រក្សាភាគហ៊ុនភាគតិចរបស់ខ្លួន។

22. បច្ចុប្បន្នធនាគារ ABBank រក្សាភាគហ៊ុន 10.31 ភាគរយនៅក្នុងក្រុមហ៊ុន EVNI ដែលខ្លួនវារក្សាភាគហ៊ុន 10 ភាគរយរបស់ខ្លួននៅក្នុង LS2 ដើម្បីទូទាត់សងសម្រាប់ការចូលរួមចំណែករបស់ពួកគេក្នុងដំណាក់កាលស្វែងយល់របស់ LS2។ នេះប្រែក្លាយទៅជាកម្មសិទ្ធិដោយប្រយោលត្រឹមតែ 1.031 ភាគរយនៅក្នុង LS2 សម្រាប់ធនាគារ ABBank ប៉ុណ្ណោះ។ ធនាគារ ABBank មិនមានទំនាក់ទំនងកិច្ចសន្យាណាមួយជាមួយក្រុមហ៊ុន Hydropower LS2 ឬមានតំណាងណាមួយនៅក្នុងក្រុមប្រឹក្សាភិបាលរបស់ខ្លួនឡើយ។

23. IFC មិនបានផ្តល់ហិរញ្ញប្បទានណាមួយឡើយ ទាំងដោយផ្ទាល់ ឬដោយប្រយោលដល់ LS2 ក្រុមហ៊ុន Hydrolancang International Energy របស់ប្រទេសចិន ក្រុមហ៊ុនរ៉ូយ៉ាល់គ្រុបនៃប្រទេសកម្ពុជា ឬក្រុមហ៊ុន EVNI។ អង្គភាពទាំងពីរមិនត្រូវបានតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ E&S ឡើយ។ ដូច្នេះ LS2 មិនអាចត្រូវបានចាត់ទុកថាជាគម្រោងវិនិយោគរបស់ IFC អនុគម្រោង ឬអនុគម្រោងរងទេ ហើយលក្ខខណ្ឌតម្រូវ E&S របស់ IFC មិនអនុវត្តចំពោះ LS2 ឡើយ។

## III. ពាក្យបណ្តឹង CAO

24. នៅក្នុងខែមិថុនា ឆ្នាំ 2018, CAO បានជូនដំណឹងដល់ IFC អំពីពាក្យបណ្តឹងចំនួនបី ដែលត្រូវបានដាក់ទៅ CAO ដោយក្រុមអ្នកភូមិបីក្រុមដាច់ដោយឡែកពីគ្នា ដែលមានទីតាំងនៅក្នុងខេត្តស្ទឹងត្រែង និងរតនគីរី នៃប្រទេសកម្ពុជា ដោយមានជំនួយពីអង្គការសង្គមស៊ីវិល (CSOs) អន្តរជាតិចំនួនបី។ ពាក្យបណ្តឹងបានអះអាងថា សហគមន៍នានាត្រូវបាន ឬអាចនឹងរងផលប៉ះពាល់ ដោយផលប៉ះពាល់បរិស្ថាន និង/ឬសង្គមដែលកើតចេញពីគម្រោង LS2 ហើយថា IFC ត្រូវបានប៉ះពាល់យ៉ាងសកម្មចំពោះគម្រោង LS2 តាមរយៈការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ Vietinbank និង ABBank។

25. CAO បានរកឃើញថាពាក្យបណ្តឹងទាំងនោះមានសិទ្ធិទទួលបាននៅក្នុងខែកក្កដា ឆ្នាំ 2018 ហើយបានចាប់ផ្តើមការវាយតម្លៃ។ រយៈពេលវាយតម្លៃ ដែលបានកំណត់នៅក្នុងគោលនយោបាយ CAO ដែល ចំណាយពេល 90 ថ្ងៃធ្វើការ ត្រូវបានពន្យារពេលជាច្រើនឆ្នាំ ដោយសារតែ

ជំងឺរាតត្បាតកូវីដ-19 និង តម្រូវការក្នុងការបង្កើតទំនាក់ទំនងជាមួយភាគី ពាក់ព័ន្ធបន្ថែម ដែលទស្សនៈរបស់ពួកគេត្រូវបានចាត់ទុកថាពាក់ព័ន្ធ។

26. ដំបូងឡើយ ដើមបណ្តឹងបានស្នើសុំឱ្យ CAO រក្សាអត្តសញ្ញាណរបស់ពួកគេជាសម្ងាត់ ដោយសារតែការព្រួយបារម្ភអំពីសន្តិសុខផ្ទាល់ខ្លួន ហើយ CAO អាចចែក រំលែកសេចក្តីសង្ខេប នៃពាក្យបណ្តឹងជាមួយ IFC បានតែនៅក្នុងខែកញ្ញា ឆ្នាំ 2021 ប៉ុណ្ណោះ។

27. បន្ទាប់ពីជិតបួនឆ្នាំ ភាគីនៃពាក្យបណ្តឹងមិនបានយល់ព្រមចូលរួមក្នុងដំណើរការដោះស្រាយ វិវាទទេហើយករណីនេះត្រូវបានផ្ទេរទៅការវាយតម្លៃការអនុលោមនៅឆ្នាំ 2022។

---

7 EVNI របាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មឆ្នាំ 2023http://evni.vn/wp-content/uploads/2024/03/Bao-cao-kiem-toan-nam- 2023_signed.pdf

28. នៅថ្ងៃទី 18 ខែវិច្ឆិកា ឆ្នាំ 2022, CAO បានបញ្ចប់របាយការណ៍វាយតម្លៃរបស់ខ្លួន ដោយសន្និដ្ឋានថា ពាក្យបណ្តឹងទាំងនោះសមនឹងទទួលបានការស៊ើបអង្កេតអនុលោមភាព ទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ទោះបីជាការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងក្នុងខែកក្កដា ឆ្នាំ 2022 ដែលបញ្ជាក់ថាមិនមានទំនាក់ ទំនងផ្ទាល់ ឬដោយ ប្រយោលរវាង IFC និងគម្រោង LS2 ក៏ដោយ។[8]

29. CAO បានឈានដល់ការសន្និដ្ឋាននេះដោយពឹងផ្អែកលើផែនការ SEMS (ឥឡូវហៅថា ESAP) នៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ដែលបានចុះហត្ថលេខារវាង IFC និងធនាគារ ABBank ដែលមានកំហុសឆ្គងក្នុងការកំណត់លក្ខខណ្ឌតម្រូវយ៉ាងទូលំទូលាយសម្រាប់ធនាគារ ABBank ទាក់ទងនឹងការអនុវត្តគោលនយោបាយ E&S របស់ IFC និងលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងផលប័ត្រដែលមានស្រាប់របស់ធនាគារ ABBank មុនពេលការវិនិយោគរបស់ IFC។ ទោះយ៉ាងណាក៏ដោយ ការតាក់តែងកិច្ចព្រមព្រៀងដែលមានកំហុសនេះមិនបានឆ្លុះបញ្ចាំងពីបំណងរបស់ភាគីនានា ឬគោលនយោបាយ E&S របស់ IFC ទេ។

30. នៅក្នុងខែសីហា ឆ្នាំ 2023, CAO បានទទួលពាក្យបណ្តឹងមួយផ្សេងទៀតទាក់ទងនឹងផលប៉ះពាល់ E&S ពី LS2 និង IFC ដែលត្រូវបានចោទប្រកាន់ថាបានប៉ះពាល់នឹងគម្រោង LS2 តាមរយៈការវិនិយោគភាគហ៊ុននៅក្នុងធនាគារប្រៃសណីយ៍ចិន (PSBC)។ CAO បានបិទសំណុំរឿងនៅពេលវាយតម្លៃ ដោយបញ្ជាក់ថា IFC មិនត្រូវបានប៉ះពាល់នឹងគម្រោង LS2 តាមរយៈការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ PSBC ទេ។[9] ដោយបញ្ជាក់ថាមានភស្តុតាងមិនគ្រប់គ្រាន់នៃទំនាក់ទំនងហិរញ្ញវត្ថុ CAO ក៏បានបិទសំណុំរឿងទាក់ទងនឹងពាក្យបណ្តឹងទាក់ទងនឹងផលប៉ះពាល់ E&S ពីគម្រោង LS2 តាមរយៈការប៉ះពាល់របស់យើងនៅក្នុងធនាគារ Vietinbank។

31. នៅខែវិច្ឆិកា ឆ្នាំ 2024, CAO បានដាក់ជូនរបាយការណ៍ស៊ើបអង្កេតអនុលោមភាពរបស់ខ្លួនទាក់ទងនឹងការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank។

## IV. ការឆ្លើយតបរបស់ថ្នាក់គ្រប់គ្រងចំពោះលទ្ធផលរកឃើញ និងអនុសាសន៍របស់ CAO

32. ផ្នែកនេះឆ្លើយតបទៅនឹងលទ្ធផលរកឃើញ និងអនុសាសន៍របស់ CAO ព្រមទាំងពន្យល់អំពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពរបស់ IFC ទាក់ទងនឹងការវិនិយោគលើភាគហ៊ុន។

### ក. ការឆ្លើយតបរបស់ IFC ចំពោះលទ្ធផលរកឃើញរបស់ CAO

33. ការវិនិយោគរបស់ IFC នៅក្នុងធនាគារ ABBank ក្នុងឆ្នាំ 2010 គឺស្ថិតនៅក្រោមគោលនយោបាយនិរន្តរភាពឆ្នាំ 2006 និង PS ដែលរួមគ្នាត្រូវបានចាត់ទុកថាជាក្របខ័ណ្ឌនិរន្តរភាពរបស់ IFC។

34. ក្របខ័ណ្ឌនិរន្តរភាពឆ្នាំ 2006 មិនបានចែងថា លក្ខខណ្ឌតម្រូវ E&S របស់ IFC ត្រូវបានអនុវត្តចំពោះផលប័ត្ររបស់អតិថិជន FI ដែលមានមុនពេលវិនិយោគរបស់ IFC ទៅលើអតិថិជន FI នោះទេ។ ក្របខ័ណ្ឌនិរន្តរភាពឆ្នាំ 2006 បានកំណត់ថា "FIs ដែលផ្តល់ហិរញ្ញប្បទានសាជីវកម្មរយៈពេលវែង ឬហិរញ្ញប្បទានគម្រោងត្រូវទាមទារឲ្យអ្នកទទួលហិរញ្ញប្បទានបែបនេះ ត្រូវ៖ (i) អនុវត្តតាមច្បាប់ជាតិ ដែលសកម្មភាពដែលទទួលបានហិរញ្ញប្បទានបង្ហាញពីហានិភ័យសង្គម ឬបរិស្ថានមានកម្រិត និង (ii) អនុវត្តបទដ្ឋានការអនុវត្ត ដែលសកម្មភាពដែលទទួល

បានហិរញ្ញប្បទានបង្ហាញពីហានិភ័យសង្គម ឬបរិស្ថានសំខាន់ៗ។”[10]លើសពីនេះ គោលនយោបាយនេះចែងថា “FI នឹងត្រូវបានទាមទារឱ្យបង្កើត និងថែរក្សាបរិស្ថាន និង

---

[8]https://www.cao-ombudsman.org/sites/default/files/downloads/CAO_Compliance%20Appraisal%20Report_Cambodia%20FI%2001-3_December%202022_EN.pdf

[9] របាយការណ៍វាយតម្លៃ CAO ឆ្នាំ 2024https://www.cao-ombudsman.org/sites/default/files/downloads/CAO-AppraisalReport-CambodiaPSBC-02-ENG-Sept2024_0.pdf

[10] គោលនយោបាយនិរន្តរភាពឆ្នាំ 2006 កថាខណ្ឌ 28 ទំព័រ 6។

ប្រព័ន្ធគ្រប់គ្រងសង្គម ដើម្បីធានាថាការវិនិយោគរបស់ខ្លួនបំពេញតាមលក្ខខណ្ឌតម្រូវរបស់ IFC ហើយ IFC នឹងត្រួតពិនិត្យការអនុវត្តរបស់ FI ដោយផ្អែកលើប្រព័ន្ធគ្រប់គ្រង។”[11] ដោយ ស្រប តាមការអនុវត្តទីផ្សារ ការវិនិយោគនៅក្នុងបរិបទនេះ ត្រូវបានគេយល់ថាសំដៅទៅលើសកម្មភាពអាជីវកម្មនាពេលអនាគត ដែលត្រូវផ្តល់មូលនិធិដោយ IFC។

35. លទ្ធផលរកឃើញរបស់ CAO ហាក់ដូចជាមិនស្របនឹងលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពឆ្នាំ 2006 ទេ។ ការអនុវត្តលក្ខខណ្ឌតម្រូវការ E&S របស់ IFC ទៅលើផលប័ត្រដែលមានស្រាប់របស់អតិថិជន FI មុនពេលការវិនិយោគរបស់ IFC មិនដែលត្រូវបានបម្រុងទុក ឬអនុវត្តឡើយ។ ទោះបីជាគោលនយោបាយនិរន្តរភាពឆ្នាំ 2006 របស់ IFC ដែលអនុវត្តនៅពេលវិនិយោគភាគហ៊ុនរបស់ IFC នៅក្នុងធនាគារ ABBank មិនមានភាពច្បាស់លាស់អំពីចំណុចនេះក៏ដោយ ក៏ការធ្វើបច្ចុប្បន្នភាពនៃក្របខ័ណ្ឌនិរន្តរភាពរបស់ IFC ក្នុងឆ្នាំ 2012 បានបញ្ជាក់ពីចំណុចផ្សេងៗអំពីរបៀបដែលលក្ខខណ្ឌតម្រូវ E&S នឹងអនុវត្តចំពោះអតិថិជន FI។ គោលនយោបាយនិរន្តរភាពឆ្នាំ 2012 បញ្ជាក់ថា ក្នុងករណីដែល IFC ផ្តល់ការគាំទ្រផ្នែកភាគហ៊ុន ឬហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ លក្ខខណ្ឌតម្រូវ “អនុវត្តចំពោះផលប័ត្ររបស់អន្តរការីហិរញ្ញវត្ថុដែល *មានប្រភពមកពីពេលដែល IFC ក្លាយជាភាគទុនិក ឬវិនិយោគិន*។”[12]

36. ការវាយតម្លៃរបស់ CAO ថា លក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពអនុវត្តចំពោះផលប័ត្ររបស់អតិថិជន FI ដែលមិនត្រូវបានផ្តល់មូលនិធិដោយ IFC គឺជារឿងគួរឱ្យព្រួយបារម្ភ។ វាមិនមែនជាលទ្ធភាពដែលអាចធ្វើទៅបានក្នុងផ្នែកពាណិជ្ជកម្ម ហើយក៏មិនស្របតាមការអនុវត្តក្នុងវិស័យឧស្សាហកម្មសកល ឬគោលនយោបាយរបស់ធនាគារ អភិវឌ្ឍន៍ពហុភាគី (MDBs) ផ្សេងទៀតនោះដែរ ក្នុងការរំពឹងទុកឱ្យអតិថិជន FI អនុវត្តលក្ខខណ្ឌតម្រូវ E&S ដោយឯកតោភាគី និង ប្រកបដោយអនុភាពប្រតិសកម្មទៅលើគម្រោងនានាដែលមានតាំងពីមុនពេលមានការវិនិយោគពី MDB នោះ។ គួរកត់សម្គាល់ផងដែរថា ក្រោមគោលការណ៍ច្បាប់ទូទៅ ច្បាប់ និងគោលនយោបាយមិនត្រូវបានអនុវត្តប្រកបដោយអនុភាពប្រតិសកម្មទេ លុះត្រាតែការអនុវត្តបែបនេះត្រូវបានគ្រោងទុក និងលើកឡើងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ ឬគោលនយោបាយពាក់ព័ន្ធ។

37. ក្នុងករណីនេះ ផលប៉ះពាល់ជាក់ស្តែងនៃការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ទៅលើផលប័ត្រដែលមានស្រាប់របស់ធនាគារ ABBank មានន័យថា ធនាគារ ABBank នឹងត្រូវចរចាឡើងវិញនូវកិច្ចសន្យាជាមួយក្រុមហ៊ុន EVNI ដែលបានធ្វើឡើង និងអនុវត្តមុនពេលការវិនិយោគរបស់ IFC។ ជាថ្នូរមកវិញ ក្រុមហ៊ុន EVNI នឹងត្រូវបានតម្រូវឱ្យចរចាឡើងវិញនូវកិច្ចសន្យា ជាមួយដៃគូរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា និងធ្វើការសិក្សាលទ្ធភាពដែលបានបញ្ចប់ឡើងវិញ រួមទាំងការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្នាំ 2008 ដើម្បីអនុវត្តតាម PSs របស់ IFC។ ជាលទ្ធផល អាជ្ញាធរកម្ពុជានឹងត្រូវពិនិត្យឡើងវិញនូវការអនុម័តគម្រោងនេះ និងចេញអាជ្ញាបណ្ណបរិស្ថានថ្មី។

38. វិធីសាស្ត្របែបនេះនឹងនាំឱ្យមានស្ថានភាពមិនអាចអនុវត្តបាន និងមិនអាចសម្រេចបានខាងពាណិជ្ជកម្ម។ គោលការណ៍ទូទៅដែលត្រូវបានអនុវត្តក្នុងការប្រើប្រាស់គោលនយោបាយរបស់ IFC គឺថា គោលនយោបាយទាំងនោះវែងឆ្ងាយ ហើយត្រូវបានយកមកអនុវត្តចំពោះការវិនិយោគរបស់ IFC នៅពេលដែលការវិនិយោគនោះត្រូវបានបង្កើតឡើង និង កន្លែងដែលមូលនិធិ IFC ត្រូវបានប្រើប្រាស់។

39. ទោះបីជាលក្ខខណ្ឌតម្រូវ E&S ដែលរួមបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់រវាង IFC និងធនាគារ ABBank ក្នុងឆ្នាំ 2010 ត្រូវបានតាក់តែងឡើងយ៉ាងទូលំទូលាយក៏ដោយ IFC

បានធ្វើសកម្មភាពរបស់ខ្លួនដោយផ្អែកលើ គោលការណ៍ណែនាំគោលនយោបាយរបស់ខ្លួន និង គោលនយោបាយនិរន្តរភាពដែលមានជាធរមាន ដែលមិនបានគិតគូរពីការអនុវត្តលក្ខខណ្ឌតម្រូវ E&S ប្រកបដោយអនុភាពប្រតិសកម្ម ចំពោះផលប័ត្រដែលមានស្រាប់នោះទេ។ សម្រាប់គោលបំណងកំណត់អនុលោមភាពតាមគោលនយោបាយស្តីពីនិរន្តរភាព ឯកសាររបស់ធនាគារ ABBank ត្រូវអានក្នុងក្របខ័ណ្ឌនៃគោលនយោបាយស្តីពីនិរន្តរភាព។ វត្តមាននៃលក្ខខណ្ឌតម្រូវ E&S ដែលមានចែងក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ រួមទាំង ESAP មិនអាចត្រូវបានបកស្រាយថាពង្រីក ឬ ដាក់កម្រិតវិសាលភាពនៃគោលនយោបាយនិរន្តរភាព ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនោះទេ។

**ខ. ទំនាក់ទំនងរបស់ IFC ទៅនឹងផលប៉ះពាល់ដែលពាក់ព័ន្ធ**

---

11 គោលនយោបាយនិរន្តរភាពឆ្នាំ 2006 កថាខណ្ឌ 29 ទំព័រ 6។

12 គោលនយោបាយនិរន្តរភាពឆ្នាំ 2012 កថាខណ្ឌ 37។

40. របាយការណ៍ស៊ើបអង្កេតរបស់ CAO កត់ត្រាបទពិសោធរបស់ដើមបណ្ដឹងទាក់ទងនឹងគម្រោង LS2។ CAO អាចទាក់ទងជាមួយអាជ្ញាធរថ្នាក់ជាតិនៅកម្ពុជា ដែលបានអនុវត្ត និង/ឬត្រួតពិនិត្យការតាំងទីលំនៅថ្មី និងការសាងសង់ទំនប់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេលប្រាំបីឆ្នាំដែល CAO បានដំណើរការពាក្យបណ្ដឹងទាំងបីទាក់ទងនឹងគម្រោង LS2, CAO មិនអាចទាក់ទងម្ចាស់ និងប្រតិបត្តិករគម្រោង LS2 បានទេ។ CAO ក៏មិនអាចទាក់ទងក្រុមហ៊ុន EVNI បានដែរ ហើយកត់សម្គាល់ថា លទ្ធផលរកឃើញរបស់ខ្លួនមិនទទួលបានអត្ថប្រយោជន៍ពីការពិនិត្យឡើងវិញពេញលេញនៃព័ត៌មានគម្រោងអំពីក្រុមហ៊ុន EVNI និងគម្រោង LS2 ទេ។[13]

41. គោលនយោបាយរបស់ CAO តម្រូវឱ្យ CAO វាយតម្លៃថា តើផលប៉ះពាល់នោះមានជាប់ពាក់ព័ន្ធនឹងការមិនអនុវត្តតាមគោលនយោបាយ E&S របស់ IFC ដែរឬទេ ក្នុងអំឡុងពេលដែលពួកគេធ្វើការរកឃើញនូវផលប៉ះពាល់នានា។ វាហាក់ដូចជាមិនច្បាស់លាស់សម្រាប់ IFC ថាតើផលប៉ះពាល់ ដែលត្រូវបានចោទប្រកាន់ដោយភាគីបណ្ដឹងមានការផ្សារភ្ជាប់យ៉ាងដូចម្ដេច ទៅនឹងការចោទប្រកាន់អំពីការមិនអនុលោមតាមគោលនយោបាយ E&S របស់ខ្លួន ដោយផ្អែកលើអង្គហេតុដែលថា គោលនយោបាយនិរន្តរភាពមិនតម្រូវឱ្យមានការអនុវត្តតាម E&S របស់ IFC ចំពោះផលប័ត្រវិនិយោគរបស់ FI មុនពេលមានការវិនិយោគរបស់ IFC នោះទេ ហើយយោងតាមចំណុចនេះ E&S របស់ IFC គឺមិនត្រូវបានយកមកអនុវត្តចំពោះក្រុមហ៊ុន EVNI ឬគម្រោង LS2 ឡើយ។

42. របាយការណ៍ CAO បង្ហាញថា IFC បានខកខានឱកាសក្នុងការទាមទារឱ្យធនាគារ ABBank អនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ចំពោះក្រុមហ៊ុន EVNI និងជាលទ្ធផលចំពោះគម្រោង LS2 ហើយនេះអាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់អ្នកដាក់ពាក្យបណ្ដឹង។ ទោះជាយ៉ាងណាក៏ដោយ CAO ទទួលស្គាល់ថា វាមិនប្រាកដថាតើការអនុវត្ត បែបនេះនឹងនាំឱ្យមានជម្រើសដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបានចោទប្រកាន់ ចំពោះសហគមន៍ដែលរងផលប៉ះពាល់ដែរឬទេ ។[14]

43. របាយការណ៍ស៊ើបអង្កេតរបស់ CAO មិនបានបញ្ជាក់បន្ថែមក្នុងន័យជាក់ស្ដែង អំពីរបៀបដែលលក្ខខណ្ឌតម្រូវនៃគោលនយោបាយនិរន្តរភាពឆ្នាំ 2006 អាចត្រូវបានអនុវត្តចំពោះគម្រោង LS2 ប្រកបដោយអនុភាពប្រតិសកម្មនោះទេ។

44. គម្រោង LS2 ត្រូវបានសាងសង់ និងដំណើរការដោយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប នៃប្រទេសកម្ពុជា និងក្រុមហ៊ុន Huaneng Group របស់ប្រទេសចិន។ ក្រុមហ៊ុនទាំងពីរមិនដែលទទួលបានហិរញ្ញប្បទានពី IFC ឬតម្រូវឱ្យអនុវត្តតាមលក្ខខណ្ឌតម្រូវ E&S របស់ IFC ឡើយ។

45. ដូច្នេះ IFC មិនយល់ស្របនឹងលទ្ធផលរកឃើញរបស់ CAO ដែលថាមានការមិនអនុលោម តាម IFC ជាមួយនឹងគោលនយោបាយ E&S របស់ខ្លួន ដែលអាចបង្ក ឬរួមចំណែកដល់ផលប៉ះពាល់ដែលជួបប្រទះទាក់ទងនឹងគម្រោង LS2 នៅកម្ពុជា។

គ. ការឆ្លើយតបរបស់ **IFC** ចំពោះអនុសាសន៍របស់ **CAO**

46. គោលនយោបាយរបស់ CAO ដែលកំណត់ដំណើរការសម្រាប់ការស៊ើបអង្កេតរបស់ CAO ចែងថា ក្នុងករណីដែល CAO រកឃើញការមិនអនុលោមតាមច្បាប់ និងផលប៉ះពាល់ពាក់ព័ន្ធ CAO ធ្វើអនុសាសន៍សម្រាប់ IFC ពិចារណានៅពេលបង្កើតសកម្មភាព MAP។ អនុសាសន៍អាចទាក់ទងនឹងការដោះស្រាយការមិនអនុលោមតាមកម្រិតគម្រោង ឬអនុគម្រោង និងផលប៉ះពាល់ពាក់ព័ន្ធ និង/ឬជំហានចាំ

បាច់ដើម្បីបង្ការការមិនអនុលោមតាមនាពេលអនាគត ដែលពាក់ព័ន្ធក្នុងកាលៈទេសៈនានា។ [15] ផ្នែករងនេះផ្តល់នូវការឆ្លើយតបរបស់ IFC ចំពោះអនុសាសន៍របស់ CAO នៅកម្រិតគម្រោង និងកម្រិតប្រព័ន្ធ។ សកម្មភាព MAP របស់ IFC ត្រូវបានបង្ហាញនៅក្នុងផ្នែក V។

**<u>អនុសាសន៍កម្រិតគម្រោង LS2</u>**

47. ដូចដែលបានបង្ហាញពីមុនមក ថ្នាក់គ្រប់គ្រងមិនយល់ស្របនឹងលទ្ធផលរកឃើញរបស់ CAO ដែលថាមានការមិនអនុលោមតាមគោលនយោបាយនិរន្តរភាព ពីព្រោះលក្ខខណ្ឌតម្រូវនៃគោលនយោបាយនេះមិនត្រូវយក មកអនុវត្តប្រកបដោយអនុភាពប្រតិសកម្មទេ។ ការដាក់បញ្ចូលលក្ខខណ្ឌតម្រូវដែលបានតាក់តែងយ៉ាងទូលំទូលាយរបស់ IFC នៅក្នុងផែនការ ESAP របស់ខ្លួន ដែលជាផ្នែកមួយនៃកិច្ចព្រមព្រៀងផ្លូវច្បាប់

---

13 របាយការណ៍ស៊ើបអង្កេត CAO ទំព័រ 22។

14 របាយការណ៍ស៊ើបអង្កេត CAO ទំព័រ 54-69។

15 គោលនយោបាយ CAO កថាខណ្ឌ 113។

មិនគួរត្រូវបានចាត់ទុកថាជាការពង្រីកវិសាលភាពនៃគោលនយោបាយនិរន្តរភាពនោះទេ។ មូលនិធិ IFC មិនត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុន EVNI ឬគម្រោង LS2 ទេ ហើយអង្គភាពទាំងពីរមិនស្ថិតនៅក្រោមលក្ខខណ្ឌតម្រូវ E&S របស់ IFC ឡើយ។ ជាលទ្ធផល IFC មិនអាចផ្តល់ជូននូវសកម្មភាព MAP ណាមួយដែលទាក់ទងនឹងគម្រោង LS2 បានទេ។

## អនុសាសន៍កម្រិតប្រព័ន្ធ

48. IFC សូមថ្លែងអំណរគុណដល់ CAO ចំពោះការវិភាគយ៉ាងហ្មត់ចត់របស់ខ្លួនលើការអនុវត្ត IFC លើការវិនិយោគ FI ក្នុងឆ្នាំ 2010។ អនុសាសន៍របស់ CAO គឺផ្អែកលើក្របខ័ណ្ឌនិរន្តរភាពឆ្នាំ 2006 និងនីតិវិធីពាក់ព័ន្ធដែលមានសុពលភាពនៅពេលវិនិយោគ។ ចាប់តាំងពីឆ្នាំ 2010 មក ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S និងរចនាសម្ព័ន្ធអភិបាលកិច្ចផ្ទៃក្នុងរបស់ IFC បានវិវត្តច្រើនគួរឲ្យកត់សម្គាល់ និងត្រូវបានពង្រឹង។ ការគ្រប់គ្រងហានិភ័យ E&S នៅ IFC ឥឡូវនេះត្រូវបានគ្រប់គ្រងដោយក្របខ័ណ្ឌនិរន្តរភាពឆ្នាំ 2012។

49. នៅខែកក្កដា ឆ្នាំ 2024, IFC បានបន្តពង្រឹងមុខងារ E&S របស់ខ្លួន ដោយធ្វើវិមជ្ឈការការធ្វើសេចក្តីសម្រេចចិត្តទៅឱ្យក្រុមការងារក្នុងតំបន់ និងពង្រឹងការគ្រប់គ្រងហានិភ័យ។ ការផ្លាស់ប្តូរទាំងនេះនឹងបន្តពង្រឹងភាពស៊ីសង្វាក់គ្នានៃភាពកម្មសិទ្ធិ និង គណនេយ្យភាពរបស់ថ្នាក់ដឹកនាំប្រចាំតំបន់ក្នុងការគ្រប់គ្រងហានិភ័យ E&S នៅទូទាំងវដ្តនៃគម្រោង ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលលើកឡើងដោយសហគមន៍ដែលរងផលប៉ះពាល់។ នៅខែមករា ឆ្នាំ 2026 រចនាសម្ព័ន្ធ E&S រួមបញ្ចូលគ្នារបស់ធនាគារពិភពលោក (WBG) ដែលមានអ្នកបង្កើតគោលនយោបាយបរិស្ថាន និងសង្គម (E&S Makers) និងអ្នកត្រួតពិនិត្យបរិស្ថាន និងសង្គម (E&S Checkers) ត្រូវបានដាក់ឱ្យប្រើប្រាស់។ រចនាសម្ព័ន្ធនេះរួមមាន (i) **អ្នកបង្កើត៖** ក្រុមការងារ E&S នៅជួរមុខប្រចាំស្ថាប័ន IFC, IBRD/IDA និង MIGA និងអង្គភាពប្រតិបត្តិការ និងគោលនយោបាយ E&S រួមរបស់ធនាគារពិភពលោក (Global WBG) និង (ii) **អ្នកត្រួតពិនិត្យ៖** អង្គភាពគ្រប់គ្រងហានិភ័យ E&S រួមរបស់ ធនាគារពិភពលោក (Global WBG)។ រចនាសម្ព័ន្ធថ្មីនេះផ្តល់នូវប្រព័ន្ធមួយដែលមានភាពរឹងមាំជាងមុនសម្រាប់ការគ្រប់គ្រងហានិភ័យតាមបែបបុរេសកម្ម (ការត្រៀមលក្ខណៈទុកជាមុន) ដែលគាំទ្រដោយក្របខ័ណ្ឌធ្វើសេចក្តីសម្រេចចិត្តដ៏សាមញ្ញ និងច្បាស់លាស់ជាងមុន ហើយស្របទៅតាមគំរូអភិបាលកិច្ចហានិភ័យរបស់ ធនាគារពិភពលោក (WBG)។ អ្នកបង្កើត និងអ្នកត្រួតពិនិត្យត្រូវបានរៀបចំឡើងដើម្បីធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាក្នុងការគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌនិរន្តរភាពនៅក្នុងរាល់ការវិនិយោគរបស់ IFC។ ភារកិច្ច និងការទទួលខុសត្រូវនានា ដើម្បីសម្រេចឱ្យបាននូវអនុលោមភាពរបស់ IFC និងរបស់អតិថិជនទៅនឹងគោលនយោបាយនិរន្តរភាព និង PSs រៀងៗខ្លួន ត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុង ESRP។

50. ESRP របស់ IFC គឺជាឯកសាររស់មួយ ដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររចនាសម្ព័ន្ធស្ថាប័ន និងមេរៀនដែលបានរៀនពីប្រតិបត្តិការរបស់ IFC។ IFC ស្វាគមន៍ចំពោះមតិកែលម្អរបស់ CAO ដែលទទួលបានពីបញ្ជីនៃបណ្តឹងនានារបស់ខ្លួន។ បច្ចុប្បន្នភាពនៃនីតិវិធី ESRP ក្នុងខែធ្នូ ឆ្នាំ 2024 បានដាក់បញ្ចូលនូវអនុសាសន៍ជាប្រព័ន្ធស្រដៀងគ្នាដែលទទួលបានពីសំណុំរឿងផ្សេងៗទៀតរបស់ CAO។[16]

51. IFC បាននិងកំពុងបង្កើនជាបន្តបន្ទាប់នូវការណែនាំសម្រាប់អតិថិជន និងបុគ្គលិកសមត្ថភាព E&S ផ្ទៃក្នុង និងនីតិវិធីសម្រាប់ការវិនិយោគ FI។ សព្វថ្ងៃនេះ IFC មានបុគ្គលិកជំនាញក្នុងការគ្រប់គ្រងហានិភ័យ E&S របស់ FI នៅក្នុងតំបន់នីមួយៗ ជាមួយនឹងការបណ្តុះបណ្តាល ចំណេះដឹង និងបទពិសោធពាក់ព័ន្ធ ដើម្បីពិនិត្យ និងតាមដានការវិនិយោគ FI។

52. *ការពិនិត្យឡើងវិញពីខាងក្រៅ*។ ការពិនិត្យឡើងវិញពីខាងក្រៅលើការទទួលខុសត្រូវផ្នែកបរិស្ថាន និងសង្គមរបស់ IFC និង MIGA រួមទាំងតួនាទី និងប្រសិទ្ធភាពរបស់ CAO (ការពិនិត្យឡើងវិញពីខាងក្រៅ) ក្នុងឆ្នាំ 2019 គឺជាព្រឹត្តិការណ៍សំខាន់មួយនៅក្នុងការវិវត្តនៃក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ E&S របស់ IFC។ ក្នុងចំណោមសកម្មភាពផ្សេងទៀត IFC បានបញ្ជាក់ពីលក្ខខណ្ឌតម្រូវ E&S សម្រាប់ FIs ដោយធ្វើបច្ចុប្បន្នភាពនីតិវិធីលើការដាក់ពាក្យសុំ PS ទៅកាន់អនុគម្រោងដោយអតិថិជន FI និងការត្រួតពិនិត្យ IFC លើអនុគម្រោងបែបនេះ។ IFC ក៏បានណែនាំឧបករណ៍វិនិច្ឆ័យ ESMS ដែលមានមូលដ្ឋានលើគេហទំព័រដើម្បីជួយវិភាគគុណភាពនៃ ESMS របស់អតិថិជន។ លើសពីនេះទៅទៀត IFC

---

[16] បច្ចុប្បន្នភាពចុងក្រោយបង្អស់នៃនីតិវិធី ESRP បានដាក់បញ្ចូលនូវការផ្លាស់ប្តូរនានាដែលត្រូវបានផ្តល់យោបល់ដោយ CAO ផ្អែកលើអនុសាសន៍ស្រដៀងគ្នានៅក្នុងសំណុំរឿងដូចខាងក្រោម៖ គម្រោង Bridge 01 ប្រទេសកេនយ៉ា គម្រោង Bridge 04 ប្រទេសកេនយ៉ា គម្រោង Awba ប្រទេសមីយ៉ាន់ម៉ា គម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង គម្រោង Titan 02 និង 03 ប្រទេសអេស៊ីប គម្រោង Salala ប្រទេសលីបេរីយ៉ា គម្រោង Masdar Baynouna ប្រទេសហ្ស៊កដានី។

បានអនុវត្តលក្ខខណ្ឌតម្រូវបង្ហាញព័ត៌មានបន្ថែម បានពង្រីកសមត្ថភាពត្រួតពិនិត្យ FI និងបានបង្កើនការត្រួតពិនិត្យគម្រោង FI។ [17]

53. *កិច្ចសហការជាមួយ CAO*។ ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ IFC ក៏ទទួលបានអត្ថប្រយោជន៍ពីកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយ CAO ផងដែរ។ នៅឆ្នាំ 2011, CAO បានផ្តួចផ្តើមការធ្វើសវនកម្មអនុលោមភាពលើការវិនិយោគក្នុងវិស័យហិរញ្ញវត្ថុរបស់ IFC។ នៅឆ្នាំ 2013, IFC បានឆ្លើយតបទៅនឹងការធ្វើសវនកម្មរបស់ CAO ជាមួយនឹងផែនការសកម្មភាពមួយ។[18]CAO បានចេញរបាយការណ៍ត្រួតពិនិត្យនៅឆ្នាំ 2014, 2015, 2017 និង 2025។[19]នៅក្នុងការឆ្លើយតបរបស់ខ្លួនចំពោះរបាយការណ៍ត្រួតពិនិត្យឆ្នាំ 2017 របស់ CAO, IFC បានពិពណ៌នាអំពីការអនុវត្តវិវត្តន៍នៅការវាយតម្លៃ និងក្នុងការត្រួតពិនិត្យ និងបានបញ្ជាក់អំពីលក្ខខណ្ឌតម្រូវបង្ហាញព័ត៌មាន E&S ដែលបានបញ្ជាក់។[20] មេរៀនដែលបានរៀនពីករណី CAO ផ្សេងទៀត និងការឆ្លើយតបរបស់ IFC ចំពោះករណីទាំងនោះ ក៏បានរួមចំណែកយ៉ាងធំធេងដល់ការពង្រឹងការគ្រប់គ្រងហានិភ័យ E&S ក្នុងការវិនិយោគ FI ផងដែរ។ ការឆ្លើយតបរបស់ IFC ចំពោះអនុសាសន៍នីមួយៗខាងក្រោមបង្ហាញពីសកម្មភាព MAP ពាក់ព័ន្ធពីករណី CAO ផ្សេងទៀត។

54. IFC កំពុងធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌនិរន្តរភាព ដែលរួមមានដំណើរការពិគ្រោះយោបល់ជាសាធារណៈជាមួយភាគីពាក់ព័ន្ធនៅជុំវិញពិភពលោក។ CAO គឺជាភាគីពាក់ព័ន្ធដ៏សំខាន់មួយនៅក្នុងដំណើរការនេះ ហើយ IFC ធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកប្រឹក្សាយោបល់របស់ CAO ដើម្បីផ្តល់ព័ត៌មានថ្មីៗ។

55. បន្ថែមលើការអភិវឌ្ឍសំខាន់ៗទាំងនេះក្នុងរយៈពេល 15 ឆ្នាំចុងក្រោយនេះ ផ្នែកខាងក្រោមនឹងរំលេចនូវសកម្មភាពពាក់ព័ន្ធមួយចំនួន ប៉ុន្តែមិនមែនទាំងអស់ទេ ដែលត្រូវបានដាក់ឱ្យអនុវត្តរួចរាល់ហើយ ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ជាប្រព័ន្ធរបស់ CAO។

**អនុសាសន៍ជាប្រព័ន្ធរបស់ CAO 1**

ពង្រឹងសមត្ថភាព និងនីតិវិធី E&S សម្រាប់ការវិនិយោគ FI ដើម្បីធានាឱ្យបាននូវការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីហានិភ័យ E&S និងសមត្ថភាពផ្នែក E&S របស់អតិថិជនក្នុងអំឡុងពេលពិនិត្យពិច័យដោយហ្មត់ចត់ និងការតាមដានត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើការសន្យា E&S ទាំងអស់ ក្នុងអំឡុងពេលត្រួតពិនិត្យ។ សមត្ថភាពគួរតែត្រូវបានអភិវឌ្ឍដើម្បីធានាថា IFC មានបុគ្គលិកជំនាញក្នុងការគ្រប់គ្រងហានិភ័យ E&S របស់ FI ជាមួយនឹងការបណ្តុះបណ្តាល ចំណេះដឹង និងបទពិសោធពាក់ព័ន្ធដើម្បីពិនិត្យ និងតាមដានការវិនិយោគ FI

56. ចាប់តាំងពីឆ្នាំ 2010 មក IFC បានអនុវត្តកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពយ៉ាងសំខាន់ ដើម្បីបង្កើនការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើការវិនិយោគ FI ការត្រួតពិនិត្យ និងការត្រួតពិនិត្យលើការប្តេជ្ញាចិត្ត E&S។ ចំនួនអ្នកឯកទេស E&S ដែលគ្របដណ្តប់លើការវិនិយោគ FI បានកើនឡើងពីប្រាំនាក់ដល់ប្រហែល 30 នាក់ រួមទាំងអ្នកជំនាញឈានមុខគេក្នុងឧស្សាហកម្ម FI ក្នុងតំបន់ចំនួនប្រាំបួននាក់។ នៅក្នុងតំបន់អាស៊ីប៉ូព៌ា ចំនួនអ្នកឯកទេស E&S ដែលផ្តោតលើប្រតិបត្តិការ FI បានកើនឡើងពីអ្នកប្រឹក្សារយៈពេលខ្លីពីរនាក់ ដល់បុគ្គលិកធម្មតាបួននាក់ ដែលទទួលបានការគាំទ្រពីអ្នកប្រឹក្សារយៈពេលខ្លីបន្ថែម។

57. នៅឆ្នាំ 2013, IFC បានពង្រីកកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យ FI របស់ខ្លួន។ បន្ថែមពីលើការត្រួតពិនិត្យប្រចាំឆ្នាំរបស់អតិថិជន FI-1 ទាំងអស់ ឥឡូវនេះ IFC ត្រួតពិនិត្យជារៀងរាល់ឆ្នាំ អតិថិជន FI-2 ទាំងអស់ដែលអនុគម្រោងរបស់ពួកគេជាកម្មវត្ថុនៃ PSs។[21] ការគាំទ្រកាន់តែច្រើនសម្រាប់អតិថិជនដែលមានហានិភ័យខ្ពស់តម្រូវឱ្យមានការរៀបចំឡើងវិញនូវធនធាន។ នៅឆ្នាំ 2018, IFC

---

17 សូមមើលការពិនិត្យឡើងវិញខាងក្រៅនៃការទទួលខុសត្រូវ E&S របស់ IFC/MIGA រួមទាំងរបាយការណ៍តួនាទី និងប្រសិទ្ធភាពរបស់ CAO និង អនុសាសន៍ឆ្នាំ 2020https://thedocs.worldbank.org/en/doc/578881597160949764-0330022020/original/ExternalReviewofIFCMIGAESAccountabilitydisclosure.pdf និងការធ្វើបច្ចុប្បន្នភាពសកម្មភាពមិនមែនគោលនយោបាយរបស់ IFC/MIGA,https://www.ifc.org/content/dam/ifc/doc/2023/202104-ifc-miga-non-policy-actions-update.pdf

18 IFC, 2013 ការគ្រប់គ្រងហានិភ័យ E&S របស់ស្ថាប័នហិរញ្ញវត្ថុនៅ IFC,https://www.cao-ombudsman.org/sites/default/files/downloads/IFCpresentationforCODE-ESRMforFIs-final.pdf។

19 CAO, 02/03/2025,https://www.cao-ombudsman.org/cases/multi-regional-cao-compliance-audit-ifcs-financial-sector-investments។

20 IFC, 2017 ការឆ្លើយតបរបស់ IFC ទៅនឹង "របាយការណ៍ត្រួតពិនិត្យលើកទីបីនៃការឆ្លើយតបរបស់ IFC ចំពោះការសវនកម្ម CAO លើសំណាករបស់ IFC ការវិនិយោគលើអន្តរការីហិរញ្ញវត្ថុភាគីទីបី"https://www.cao-ombudsman.org/sites/default/files/downloads/IFCResponsetoCAOThirdFIMonitoringMarch2017.pdf។

21 IFC វាយតម្លៃការវិនិយោគ FI សម្រាប់ហានិភ័យ E&S ជាហានិភ័យខ្ពស់ FI-1 ហានិភ័យមធ្យម FI-2 និងហានិភ័យទាប FI-2។

បានកែសម្រួលឡើងវិញនូវវិធីសាស្ត្រវាយតម្លៃហានិភ័យ E&S ដើម្បីសម្រួលដល់ដំណើរការវាយតម្លៃ និងតាមដានត្រួតពិនិត្យសម្រាប់អតិថិជន FI ដែលមានហានិភ័យទាប និងមធ្យមកម្រិតទាប ហើយតាមរយៈនេះគឺអនុញ្ញាតឱ្យស្ថាប័នអាចបែងចែកធនធានបន្ថែមទៀតទៅលើអតិថិជន FI ដែលមានហានិភ័យខ្ពស់ និងមធ្យមកម្រិតខ្ពស់។ ចាប់តាំងពីឆ្នាំ 2019 មក បញ្ជីហានិភ័យខ្ពស់របស់ FI ត្រូវបានបង្កើតឡើង និងតាមដានត្រួតពិនិត្យដោយមន្ត្រីទទួលបន្ទុកហានិភ័យ E&S របស់ FI នាំមុខគេ ដែលពួកគាត់ក៏បានអមដំណើរជាមួយអ្នកឯកទេសផ្នែក E&S ប្រចាំតំបន់ក្នុងការចុះទៅពិនិត្យតាមដានដោយផ្ទាល់ផងដែរ។

58. បុគ្គលិក E&S ទទួលបានការបណ្តុះបណ្តាលជាប្រចាំលើ PSs និងនីតិវិធីរបស់ IFC រួមទាំងកម្មវិធីណែនាំបុគ្គលិកចូលបម្រើការងារ ក៏ដូចជាការកសាងសមត្ថភាពក្នុងតំបន់។ វគ្គបណ្តុះបណ្តាលពាក់ព័ន្ធថ្មីៗមួយចំនួនដែលផ្តោតលើ FI សម្រាប់អ្នកឯកទេស E&S ត្រូវបានធ្វើឡើងជាផ្នែកមួយនៃព្រឹត្តិការណ៍បណ្តុះបណ្តាលជាប្រចាំតាមក្រសួង និងសិក្ខាសាលា FI រួមទាំងសិក្ខាសាលា FI រយៈពេលមួយសប្តាហ៍នៅទីក្រុងបាងកកក្នុងឆ្នាំ 2024 សិក្ខាសាលា FI រយៈពេលបីថ្ងៃនៅទីក្រុងអ៊ីស្តង់ប៊ុលក្នុងឆ្នាំ 2025 និងវគ្គបណ្តុះបណ្តាល FI នៅក្នុងទីក្រុងវ៉ាយែនបូហ្គោតា និងគៃរក្នុងឆ្នាំ 2025 និង 2026។

59. ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា MAPs របស់ IFC ដែលឆ្លើយតបទៅនឹងការស៊ើបអង្កេត CAO ផ្សេងទៀតក៏រួមបញ្ចូលទាំងការបណ្តុះបណ្តាលបុគ្គលិក និងអតិថិជនពាក់ព័ន្ធ និងគំនិតផ្តួចផ្តើមកសាងសមត្ថភាពផងដែរ។ នៅក្នុងផែនការ MAP របស់ខ្លួនជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតលើគម្រោង Bridge 4 ក្នុងប្រទេសកេនយ៉ា ស្ថាប័ន IFC បានបង្កើតនូវសេចក្តីណែនាំសម្រាប់នាយកតែងតាំងដោយ IFC។ ចាប់តាំងពីខែតុលា ឆ្នាំ 2023 មក នាយកតែងតាំងដោយ IFC ថ្មីៗទទួលបាននូវការណែនាំអំពីការពិនិត្យមើលឡើងវិញនូវហានិភ័យ E&S។ វគ្គបណ្តុះបណ្តាលគោលដៅពីរលើកដំបូងស្តីពីអភិបាលកិច្ចហានិភ័យនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (GBV Risk Governance) សម្រាប់នាយកតែងតាំងដោយ IFC បានប្រព្រឹត្តទៅក្នុងខែមករា និងខែមិថុនា ឆ្នាំ 2024។ វគ្គបណ្តុះបណ្តាលទាំងនេះនឹងត្រូវបន្តអនុវត្តដោយមានការរំលឹកឡើងវិញជាប្រចាំឆ្នាំ។[22]

**អនុសាសន៍ជាប្រព័ន្ធរបស់ CAO 2**

បង្កើត និងផ្សព្វផ្សាយក្នុងចំណោមបុគ្គលិក E&S នូវការណែនាំលម្អិតស្តីពីលក្ខខណ្ឌតម្រូវនៃការវាយតម្លៃដោយហ្មត់ចត់នៃ E&S សម្រាប់ការវិនិយោគគោលបំណងទូទៅរបស់អតិថិជន FI ដូចជាការវិនិយោគលើភាគហ៊ុនជាដើម។ ក្នុងចំណោមផ្សេងទៀត ការណែនាំនេះគួរតែរួមបញ្ចូលការណែនាំជាក់លាក់ស្តីពី៖

ក. របៀបពិនិត្យឡើងវិញនូវគំរូតំណាងនៃការវិនិយោគ ប្រតិបត្តិការ ផលិតផល និងវិស័យដែលមានហានិភ័យខ្ពស់នៅក្នុងផលប័ត្ររបស់ FI ក្នុងអំឡុងពេលធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ ដើម្បីកំណត់សមត្ថភាព E&S ដែលត្រូវការសម្រាប់អតិថិជន និងដើម្បីកំណត់ថ្លៃដើមនៃ ESAP របស់គម្រោង និងការចំណាយប្រចាំឆ្នាំជាមធ្យមនៃការអនុវត្ត ESMS របស់អតិថិជន។

ខ. របៀបវាយតម្លៃបុគ្គលិក E&S ចាំបាច់ជាអប្បបរមាដែលត្រូវការសម្រាប់ FI ដោយផ្អែកលើហានិភ័យ E&S នៃផលប័ត្រ និងការផ្លាស់ប្តូរបុគ្គលិក និងសមត្ថភាពរបស់ FI ក្នុងការទទួលយកបុគ្គលិក E&S ថ្មី។ ក្នុងករណីនេះ និងករណីផ្សេងទៀត CAO បានសង្កេតឃើញថា ចំណុចខ្វះខាតនៅក្នុងសមត្ថភាព E&S របស់អតិថិជន ជារឿយៗជា

បញ្ហាដែលកើតឡើងម្តងហើយម្តងទៀត។ IFC គួរតែបង្កើតឧបករណ៍ និងប៉ារ៉ាម៉ែត្រសម្រាប់បុគ្គលិក E&S របស់ខ្លួន ដើម្បីវាយតម្លៃតម្រូវការបុគ្គលិក E&S របស់អតិថិជនទាក់ទងនឹងផលប័ត្រហានិភ័យ E&S របស់អតិថិជន។

60. ចាប់តាំងពីឆ្នាំ 2010 មក ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌនិរន្តរភាពរបស់ IFC ក្នុងឆ្នាំ 2012 បានបញ្ជាក់ពីលក្ខខណ្ឌតម្រូវ E&S ជាច្រើនលើការពិនិត្យពិច័យ និងការត្រួតពិនិត្យសម្រាប់ទាំងបុគ្គលិក និងអតិថិជនរបស់ IFC។ IFC ក៏បានបង្កើតកំណត់ចំណាំបកស្រាយ FI ក្នុងឆ្នាំ 2012 ដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ 2018 ហើយបន្ទាប់មកត្រូវបានជំនួសដោយកំណត់ចំណាំណែនាំថ្មីមួយស្តីពី FIs ក្នុងឆ្នាំ 2023 ផងដែរ។ កំណត់ចំណាំណែនាំនេះកំណត់ដើម្បី (i) បញ្ជាក់បន្ថែមអំពីអ្វីដែលត្រូវបានចាត់ទុកថាជាប្រតិបត្តិការហានិភ័យ E&S ខ្ពស់ជាង (ii) រួមបញ្ចូលនិយមន័យនៃប្រតិបត្តិការហានិភ័យ E&S ខ្ពស់ជាងនៅក្នុងលក្ខណៈវិនិច្ឆ័យដែលប្រើដោយ FIs ដើម្បីកំណត់ប្រតិបត្តិការប្រភេទទាំងនេះ (iii) បញ្ជាក់ពីកាលៈទេសៈដែលតម្រូវឱ្យមានការយកចិត្តទុកដាក់លើ FI កាន់តែប្រសើរឡើង (iv) កំណត់ការទទួលខុសត្រូវ E&S របស់អតិថិជន FI ទាក់ទងនឹងអនុគម្រោង និងអនុគម្រោងរង (v) កំណត់ការប្តេជ្ញាចិត្តក្នុងការបង្ហាញព័ត៌មានអនុគម្រោង និង (vi) បង្កើនភាពច្បាស់លាស់លើវិសាលភាពនៃការអនុវត្តលក្ខខណ្ឌតម្រូវ E&S រួមទាំង PSs របស់ IFC ដោយអតិថិជន FI សម្រាប់ប្រតិបត្តិការហានិភ័យ E&Sខ្ពស់ជាង។

22 របាយការណ៍វឌ្ឍនភាពស្តីពីការគ្រប់គ្រង IFC ស្តីពីការអនុវត្តសកម្មភាព MAP សម្រាប់គម្រោង Bridge 04 ខែតុលា ឆ្នាំ 2024 https://www.cao-ombudsman.org/sites/default/files/downloads/IFC-ManagementProgressReport-BIA04-Oct2024-ENG.pdf

61. ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ IFC បានបង្កើត និងពង្រឹង ESRP របស់ខ្លួន ដែលភ្ជាប់មកជាមួយនឹងសន្លឹកណែនាំដែលផ្តល់ការណែនាំសម្រាប់បុគ្គលិក IFC ក្នុងការស៊ើបសួរអំពីបរិស្ថាន និងសង្គម (ESDD) និងការត្រួតពិនិត្យសម្រាប់ការវិនិយោគ FI។ បច្ចុប្បន្នភាពពាក់ព័ន្ធរួមមាន៖ (i) ការពង្រឹងសូចនាករការអនុវត្តការត្រួតពិនិត្យសំខាន់ៗ (ii) ភាពច្បាស់លាស់លើនីតិវិធីវាយតម្លៃហានិភ័យសម្រាប់ប្រតិបត្តិការ FI (iii) ការណែនាំសម្រាប់អ្នកឯកទេសអំពីពេលដែលតម្រូវឱ្យមានការពង្រឹងការត្រួតពិនិត្យ ESDD របស់ FI (iv) លក្ខខណ្ឌតម្រូវដើម្បីផ្ទៀងផ្ទាត់ធនធានអតិថិជនសម្រាប់ការអនុវត្ត ESMS ជាផ្នែកមួយនៃ ESAP (v) ការពង្រឹងការផ្ទៀងផ្ទាត់ការអនុវត្ត ESMS ជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃការបើកផ្តល់ប្រាក់កម្ចី និង (vi) ការណែនាំដែលប្រសើរឡើងសម្រាប់អ្នកឯកទេសលើឧបករណ៍វាយតម្លៃហានិភ័យ និងការអនុវត្តរបស់ពួកគេ។ នៅក្នុងការធ្វើបច្ចុប្បន្នភាព ESRP ក្នុងខែធ្នូ ឆ្នាំ 2024 ដែលបានឆ្លុះបញ្ចាំង ក្នុងចំណោមការផ្លាស់ប្តូរផ្សេងទៀត មេរៀនដែលបានរៀនពីករណី CAO ថ្មីៗ។[23]

62. អ្នកឯកទេសនាំមុខគេផ្នែកបរិស្ថាន និងសង្គម (LESS) របស់ IFC ទទួលខុសត្រូវចំពោះគុណភាព និងសង្គតភាពនៃផែនការ ESAP មុនពេលវាត្រូវបានដាក់ជូនសម្រាប់វាយតម្លៃ និងដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងវិនិយោគ។ អតិថិជនត្រូវបានស្នើសុំឱ្យរៀបចំការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់ការអនុវត្ត ESAP និងចែករំលែកការប៉ាន់ប្រមាណទាំងនេះជាមួយ IFC។ អ្នកឯកទេស LESS រួមជាមួយក្រុមវិនិយោគពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃការប៉ាន់ប្រមាណថ្លៃចំណាយរបស់អតិថិជនសម្រាប់ការអនុវត្តគម្រោង ESAP ហើយតាមតម្រូវការ នឹងចូលរួមជាមួយអតិថិជន ប្រសិនបើមានការព្រួយបារម្ភអំពីសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់ធនធានដែលត្រូវការ ឬការយល់ដឹងរបស់ខ្លួនអំពីតម្រូវការបែបនេះ។

63. IFC គូសបញ្ជាក់ថា សកម្មភាព MAP របស់ខ្លួនជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ CAO លើគម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង រួមមានវិធានការដើម្បីបង្កើតការណែនាំ និងពង្រឹងដំណើរការត្រួតពិនិត្យផ្ទៃក្នុង៖ (i) ដើម្បីពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃការប៉ាន់ប្រមាណធនធានរបស់អតិថិជនសម្រាប់ការអនុវត្តគម្រោង ESAP ដូចដែលតម្រូវនៅក្នុង PS1 (2012) កថាខ័ណ្ឌទី 16 និង (ii) ដើម្បីកត់ត្រាការពិនិត្យឡើងវិញជាផ្នែកមួយនៃឯកសារវាយតម្លៃ។ ជាលទ្ធផល ESRP និងការណែនាំដែលត្រូវគ្នាត្រូវបានធ្វើបច្ចុប្បន្នភាព។ ការបណ្តុះបណ្តាលត្រូវបានផ្តល់ជូនសម្រាប់បុគ្គលិកសំខាន់ៗផ្នែក E&S នៅថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2024 ដើម្បីចែករំលែកការណែនាំជាក់លាក់អំពីអ្វីដែលរំពឹងទុកពី LESS និងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ ប្រព័ន្ធពិនិត្យ និងចងក្រងឯកសារ E&S នៃគម្រោងរបស់ IFC គឺ ESG360 រួមបញ្ចូលម៉ូឌុលស្តីពីការតាមដាន ESAP ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបញ្ចូលការប៉ាន់ស្មានថ្លៃចំណាយ ESAP។[24]

64. នៅឆ្នាំ 2025, IFC បានបង្កើតការណែនាំសម្រាប់បុគ្គលិក E&S អំពីរបៀបពិនិត្យមើលឡើងវិញនូវគំរូតំណាងនៃការវិនិយោគដែលមានហានិភ័យខ្ពស់នៅក្នុងប្រតិបត្តិការ FI។ CAO បានផ្តល់មតិកែលម្អ និងមតិចូលរួម។

65. IFC ស្វាគមន៍ចំពោះការផ្តល់យោបល់របស់ CAO ដើម្បីពង្រឹងការណែនាំអំពីការវាយតម្លៃតម្រូវការសមត្ថភាពរបស់អតិថិជន FI និងរួមបញ្ចូលសកម្មភាព MAP ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍នេះ។ សូមមើលផ្នែកទី VI ខាងក្រោម។

| **អនុសាសន៍ជាប្រព័ន្ធរបស់ CAO 3** |
|---|
| ធ្វើការពិនិត្យឡើងវិញនូវផលប័ត្រនៃការវិនិយោគ FI ភាគហ៊ុនសកម្មរបស់ IFC ចាប់តាំងពីឆ្នាំ 2006 ដែលរួមបញ្ចូលកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ (ESAP ឬកន្លែងផ្សេងទៀត) សម្រាប់អតិថិជនដើម្បីអនុវត្ត ESMS របស់ខ្លួនចំពោះ "ប្រាក់កម្ចីដែលមានស្រាប់ និងការវិនិយោគ" និងធានាថា ការត្រួតពិនិត្យគ្រប់គ្រាន់នៃការប្តេជ្ញាចិត្តផ្នែកច្បាប់ត្រូវបានអនុវត្ត។ |

66. ថ្នាក់គ្រប់គ្រងចាត់ទុកថា អនុសាសន៍ CAO នេះមិនពាក់ព័ន្ធទេ ពីព្រោះមិនមានបញ្ហាអនុលោមភាពជាប្រព័ន្ធដែលត្រូវដោះស្រាយឡើយ។ ដូចដែលបានពិពណ៌នាខាងលើ ទោះបីជាលក្ខខណ្ឌតម្រូវដែលដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងស្របច្បាប់រវាង IFC និងធនាគារ ABBank ក្នុងឆ្នាំ 2010 មានលក្ខណៈទូលំទូលាយដោយភាន់ច្រឡំក៏ដោយ ការពិនិត្យឡើងវិញរបស់ IFC ត្រូវបាន

---

23 បច្ចុប្បន្នភាព ESRP ឆ្នាំ 2024 បានដាក់បញ្ចូលការផ្លាស់ប្តូរដែលបានស្នើឡើងដោយ CAO លើអនុសាសន៍ស្រដៀងគ្នានេះ ក្នុងករណីដូចខាងក្រោម៖ គម្រោង Bridge 01 ប្រទេសកេនយ៉ា គម្រោង Bridge 04 ប្រទេសកេនយ៉ា គម្រោង Awba ប្រទេសមីយ៉ាន់ម៉ា គម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង គម្រោង Titan 02 និង 03 ប្រទេសអេស៊ីប
គម្រោង Salala ប្រទេសលីបេរីយ៉ា គម្រោង Masdar Baynouna ប្រទេសហ្ស៊កដានី។

24 របាយការណ៍វឌ្ឍនភាពស្តីពីការគ្រប់គ្រង IFC ស្តីពីការអនុវត្តសកម្មភាព MAP សម្រាប់គម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង ខែមករា ឆ្នាំ 2024 https://www.cao-ombudsman.org/cases/south-africa-lonmin-02marikana។

ដឹកនាំដោយគោលនយោបាយនិរន្តរភាព ដូច្នេះហើយមិនមានការមិនអនុលោមតាមគោលនយោបាយនិរន្តរភាពរបស់ IFC ឡើយ។ កិច្ចព្រមព្រៀងផ្លូវច្បាប់ត្រូវអានក្នុងក្របខ័ណ្ឌនៃគោលនយោបាយនិរន្តរភាព ហើយការបកស្រាយ និងការអនុវត្តរបស់ពួកគេមិនអាចផ្ទុយនឹងស្មារតី និងខ្លឹមសារនៃគោលនយោបាយដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនោះទេ។

67. ដោយពិចារណាថាគោលនយោបាយនិរន្តរភាពឆ្នាំ 2006 និង 2012 មិនបានចែងអំពីការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ប្រកបដោយអនុភាពប្រតិសកម្មចំពោះផលប័ត្រ FIs ដែលមានស្រាប់នោះទេ ក្នុងករណីដែលលក្ខខណ្ឌតម្រូវបែបនេះត្រូវបានតាក់តែងឡើងយ៉ាងទូលំទូលាយដោយច្រឡំ IFC មិនមិនបានអនុវត្ត ហើយនឹងមិនអនុវត្តបទប្បញ្ញត្តិបែបនេះទេ។

68. នៅក្នុងបរិបទនេះ IFC បានគូសបញ្ជាក់ថា គោលនយោបាយនិរន្តរភាពឆ្នាំ 2012 បញ្ជាក់ថា ក្នុងករណីដែល IFC ផ្តល់ការគាំទ្រផ្នែកភាគហ៊ុន ឬហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ លក្ខខណ្ឌតម្រូវអនុវត្តចំពោះផលប័ត្ររបស់អន្តរការីហិរញ្ញវត្ថុដែល មានប្រភពមកពីពេលដែល IFC ក្លាយជាភាគទុនិក ឬវិនិយោគិន។[25]

69. IFC បានពិនិត្យមើលឡើងវិញ និងបានធ្វើបច្ចុប្បន្នភាពគំរូកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន ព្រមទាំងបានកែសម្រួលពួកវា ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយដែលមានចែងក្នុងផ្នែកទី 37 នៃគោលនយោបាយនិរន្តរភាពឆ្នាំ 2012។

70. លើសពីនេះ ក្នុងនាមជាផ្នែកមួយនៃសកម្មភាព MAP របស់ IFC ជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ CAO លើ RCBC ប្រទេសហ្វីលីពីន IFC បានបង្កើត និងផ្សព្វផ្សាយកំណត់ចំណាំការអនុវត្តល្អសម្រាប់អតិថិជន និងបុគ្គលិកលើកិច្ចព្រមព្រៀងផ្លូវច្បាប់ E&S គំរូក្នុងការវិនិយោគ FI។[26] សន្លឹកណែនាំសម្រាប់ FI ត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័រ IFC ក្នុងខែមីនា ឆ្នាំ 2023 ហើយអាចចូលមើលបានសម្រាប់សាធារណជន។[27]

> **អនុសាសន៍ជាប្រព័ន្ធរបស់ CAO 4**
> ធ្វើបច្ចុប្បន្នភាព ESRP របស់ខ្លួន ដើម្បីផ្តល់ការណែនាំកាន់តែច្បាស់លាស់ដល់បុគ្គលិក E&S អំពីរបៀបរៀបចំរចនាសម្ព័ន្ធ ការវិនិយោគដើម្បីប្រើប្រាស់អានុភាពរបស់ IFC ឲ្យបានល្អបំផុតក្នុងអំឡុងពេលវិនិយោគ ដើម្បីធានាបាននូវ អនុលោមភាពរបស់អតិថិជនតាមលក្ខខណ្ឌតម្រូវ E&S។ ដូចដែលបានផ្តល់អនុសាសន៍នៅក្នុងករណីមុនៗ នេះគួរតែរួមបញ្ចូលការណែនាំច្បាស់លាស់អំពីតម្រូវការក្នុងការភ្ជាប់ការប្តេជ្ញាចិត្ត E&S នៅក្នុងគម្រោង ESAP ឬ កិច្ចព្រមព្រៀងស្របច្បាប់ចំពោះដំណាក់កាលសំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការបើកផ្តល់ប្រាក់កម្ចីលើកដំបូង និងការបើកផ្តល់ប្រាក់កម្ចីជាបន្តបន្ទាប់ ដើម្បីធានាថា IFC មានអានុភាពគ្រប់គ្រាន់ដើម្បីទាមទារឲ្យមានការបញ្ចប់។

71. ដូចដែលបានពន្យល់ខាងលើ ESRP របស់ IFC គឺជាឯកសាររស់មួយដែលត្រូវបានរក្សាបច្ចុប្បន្នភាពដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររចនាសម្ព័ន្ធស្ថាប័ន និងមេរៀនដែលបានរៀនពីប្រតិបត្តិការរបស់ IFC។ ក្នុងខែធ្នូ ឆ្នាំ 2024 បច្ចុប្បន្នភាពនៃនីតិវិធី

ESRP ត្រូវបានដាក់បញ្ចូលនូវអនុសាសន៍ជាប្រព័ន្ធស្រដៀងគ្នាដែលទទួលបានពីសំណុំរឿងផ្សេងៗទៀតរបស់ CAO។[28]

72. ដូចដែលបានរៀបរាប់ខាងលើផងដែរ IFC បានធ្វើបច្ចុប្បន្នភាព FI ទៅលើគម្រោង ESRP និងសន្លឹកណែនាំដែលត្រូវគ្នា ដែលរួមមាន៖ (i) ការពង្រឹងសូចនាករការអនុវត្តការត្រួតពិនិត្យសំខាន់ៗ (ii) ភាពច្បាស់លាស់លើនីតិវិធីវាយតម្លៃហានិភ័យសម្រាប់ប្រតិបត្តិការ FI (iii) ការណែនាំសម្រាប់អ្នកឯកទេសអំពីពេលដែលតម្រូវឱ្យមានការពង្រឹងការត្រួតពិនិត្យ ESDD របស់ FI (iv) លក្ខខណ្ឌតម្រូវដើម្បីផ្ទៀងផ្ទាត់ធនធានអតិថិជនសម្រាប់ការអនុវត្ត ESMS ជាផ្នែកមួយនៃ ESAP (v) ការពង្រឹងការផ្ទៀងផ្ទាត់ការអនុវត្ត ESMS

---

25 2012 SP កថាខណ្ឌ 37។

26 របាយការណ៍វឌ្ឍនភាពស្តីពីការគ្រប់គ្រងរបស់ IFC លើកទី 3 ស្តីពីការអនុវត្តសកម្មភាព MAP សម្រាប់ RCBC ប្រទេសហ្វីលីពីន ខែវិច្ឆិកា ឆ្នាំ2024 https://www.cao-ombudsman.org/cases/philippines-rizal-commercial-banking-corporation-rcbc-01។

27 IFC ឆ្នាំ 2023 សន្លឹកណែនាំសម្រាប់អន្តរការីហិរញ្ញវត្ថុ https://documents1.worldbank.org/curated/en/099442503092324349/pdf/IDU040b830730f0c3047070bce0007c5bc473641.pdf។

28 បច្ចុប្បន្នភាព ESRP ឆ្នាំ 2024 បានដាក់បញ្ចូលការផ្លាស់ប្តូរដែលបានស្នើឡើងដោយ CAO លើអនុសាសន៍ស្រដៀងគ្នានេះ

ក្នុងករណីដូចខាងក្រោម៖ គម្រោង Bridge 01 ប្រទេសកេនយ៉ា គម្រោង Bridge 04 ប្រទេសកេនយ៉ា គម្រោង Awba ប្រទេសមីយ៉ាន់ម៉ា គម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង គម្រោង Titan 02 និង 03 ប្រទេសអេស៊ីប គម្រោង Salala ប្រទេសលីបេរីយ៉ា គម្រោង Masdar Baynouna ប្រទេសហ្ស៊កដានី។

ជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃការបើកផ្តល់ប្រាក់កម្ចី និង (vi) ការណែនាំដែលប្រសើរឡើងសម្រាប់អ្នកឯកទេសលើឧបករណ៍វាយតម្លៃហានិភ័យ និងការអនុវត្តរបស់ពួកគេ។ ស្ថាប័ន IFC ក៏បានបង្កើតនូវឧបករណ៍វិនិច្ឆ័យប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS Diagnostics Tool) និងបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ដើម្បីបង្កើនភាពស៊ីចង្វាក់គ្នាក្នុងការរៀបចំ និងការអនុវត្តប្រព័ន្ធ ESMSs របស់អតិថិជន FI។

73. ដើម្បីពង្រឹងការអនុវត្តគម្រោង ESRP ឱ្យមានប្រសិទ្ធភាព ស្ថាប័ន IFC បានស្នើនូវសកម្មភាព MAP ថ្មី ដែលនឹងបង្កើតការណែនាំសម្រាប់ទាំងការវិនិយោគ និងបុគ្គលិក E&S ដើម្បីប្រើប្រាស់អានុភាពរបស់ខ្លួនឱ្យកាន់តែប្រសើរនៅក្នុងគម្រោង FI ផ្សេងៗគ្នា រួមទាំងការណែនាំច្បាស់លាស់ស្តីពីការផ្សារភ្ជាប់ការប្តេជ្ញាចិត្ត E&S នៅក្នុងគម្រោង ESAP ទៅនឹងដំណាក់កាលសំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការបើកផ្តល់ប្រាក់កម្ចីលើកដំបូង និងការបើកផ្តល់ប្រាក់កម្ចីជាបន្តបន្ទាប់។

## V. ការពិគ្រោះយោបល់ជាមួយក្រុមហ៊ុន និងអ្នកដាក់ពាក្យបណ្តឹង

74. យោងតាមគោលនយោបាយរបស់ CAO ក្នុងអំឡុងពេលរៀបចំសកម្មភាព MAP ស្ថាប័ន IFC ពិគ្រោះយោបល់ជាមួយអ្នកដាក់ពាក្យបណ្តឹង និងអតិថិជន។ ក្នុងករណីនេះ IFC បានជម្រាបជូនតំណាងអ្នកដាក់ពាក្យបណ្តឹងថា IFC មិនអាចផ្តល់សកម្មភាពជាក់លាក់ណាមួយលើគម្រោងដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO បានទេ។

### <u>ការពិគ្រោះយោបល់ជាមួយអ្នកដាក់ពាក្យបណ្តឹង</u>

75. ក្រុមអ្នកភូមិទាំងបីក្រុមដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយគម្រោង LS2 ត្រូវបានតំណាងដោយអង្គការសង្គមស៊ីវិលអន្តរជាតិចំនួនបីគឺ អង្គការទន្លេអន្តរជាតិ អង្គការគម្រោងគណនេយ្យភាពអន្តរជាតិ និងអង្គការឃ្លាំមើលទន្លេមេគង្គ។

76. នៅឆ្នាំ 2022 ក្នុងអំឡុងពេលនៃការវាយតម្លៃលើអនុលោមភាពតាមបទប្បញ្ញត្តិ IFC បានចូលរួមពិភាក្សាជាមួយទាំងតំណាងរបស់អ្នកដាក់ពាក្យបណ្តឹង និងសមាជិកសហគមន៍ដោយផ្ទាល់។ ក្នុងកិច្ចប្រជុំតាមអនឡាញ IFC បានពន្យល់ថា ទំនាក់ទំនងរបស់ធនាគារ ABBank ជាមួយក្រុមហ៊ុន EVNI និងគម្រោង LS2 មានតាំងពីមុនពេលការវិនិយោគរបស់ IFC មកម្ល៉េះ ហើយគោលនយោបាយ E&S របស់ IFC មិនត្រូវបានអនុវត្តដោយមានអនុភាពប្រតិសកម្មនោះទេ។

77. នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតឯករាជ្យរបស់ក CAO (ឆ្នាំ 2022-2024) IFC មិនបានចូលរួមពិភាក្សាជាមួយអ្នកដាក់ពាក្យបណ្តឹង ឬតំណាងរបស់ពួកគេនោះទេ។

78. ក្នុងអំឡុងពេលរៀបចំរបាយការណ៍គ្រប់គ្រង និងសកម្មភាព MAP នេះ IFC បានធ្វើកិច្ចប្រជុំតាមអនឡាញមួយជាមួយតំណាងរបស់អ្នកដាក់ពាក្យបណ្តឹង ដើម្បីជម្រាបជូនពួកគេថា គោលជំហររបស់ IFC មិនមានការផ្លាស់ប្តូរនោះទេ។ តំណាងរបស់អ្នកដាក់ពាក្យបណ្តឹងបានពន្យល់ថា ពួកគេត្រូវការភាពច្បាស់លាស់ជាមុនសិនអំពីការដែលថាតើ IFC អាចផ្តល់នូវសកម្មភាពជាក់លា

ក់ណាមួយសម្រាប់គម្រោងនេះដែរឬទេ មុនពេលដែលពួកគេធ្វើការ ទាក់ទងទៅកាន់អ្នកដាក់ពាក្យបណ្តឹងដោយផ្ទាល់។

79. នៅក្នុងខែកុម្ភៈ ឆ្នាំ 2025, IFC បានជម្រាបជូនតំណាងអ្នកដាក់ពាក្យបណ្តឹងថា IFC មិនអាចផ្តល់សកម្មភាពជាក់លាក់ណាមួយសម្រាប់គម្រោង ណាមួយដើម្បីឆ្លើយតបទៅនឹងអនុសាសន៍របស់ CAO បានទេ។

80. IFC យល់ពីការខកចិត្តរបស់អ្នកដាក់ពាក្យបណ្តឹង ហើយសូមថ្លែងអំណរគុណដល់ពួកគេ និងតំណាងរបស់ពួកគេចំពោះការអត់ធ្មត់ និងឆន្ទៈក្នុងការចូលរួមក្នុងដំណើរការ CAO នេះ។ ថ្នាក់គ្រប់គ្រងមានការសោកស្តាយដែលការស៊ើបអង្កេតរបស់ CAO បានបង្កើតការរំពឹងទុកក្នុងចំណោមអ្នកដាក់ពាក្យបណ្តឹង និងអ្នកតំណាងរបស់ពួកគេសម្រាប់សកម្មភាពកែតម្រូវទាក់ទងនឹងអនុគម្រោងរងដែល IFC មិនបានផ្តល់ហិរញ្ញប្បទាន។

**<u>ជំហររបស់ក្រុមហ៊ុន</u>**

81. ធនាគារ ABBank អះអាងថា ខ្លួនមិនមានទំនាក់ទំនងកិច្ចសន្យា ឬអាជីវកម្មជាមួយអនុគម្រោងរងនៅក្នុងប្រទេសកម្ពុជាទេ ហើយមិនអាចចាត់វិធានការណាមួយដើម្បីឆ្លើយតបទៅនឹងពាក្យបណ្ដឹងរបស់ CAO ដែលទទួលបានក្នុងឆ្នាំ 2018 នោះដែរ។ ធនាគារ ABBank កាន់កាប់ភាគហ៊ុន 10.31 ភាគរយនៅក្នុងក្រុមហ៊ុន EVNI ដែលខ្លួនវាផ្ទាល់មានភាគហ៊ុន 10 ភាគរយនៃគម្រោងទំនប់ LS2។ វាមានន័យថា ជាការប្រឈមដោយប្រយោលដែលមានកម្រិតត្រឹមតែ 1.031 ភាគរយប៉ុណ្ណោះ។ ក្រុមថ្នាក់គ្រប់គ្រងបច្ចុប្បន្នរបស់ធនាគារ ABBank បានបញ្ជាក់ពីការយល់ឃើញរបស់ខ្លួនថា លក្ខខណ្ឌតម្រូវ E&S របស់ IFC ត្រូវអនុវត្តចំពោះតែកម្ចី និងការវិនិយោគទាំងឡាយណាដែលបានធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងជាមួយ IFC ប៉ុណ្ណោះ។ ការយល់ឃើញនេះគឺស្របទៅនឹងគោលការណ៍ទូទៅនៃអានុភាពប្រតិសកម្ម ពោលគឺបទប្បញ្ញត្តិត្រូវអនុវត្តសម្រាប់ពេលអនាគត ហើយមិនមានអានុភាពប្រតិសកម្មត្រឡប់ទៅក្រោយវិញនោះទេ លើកលែងតែមានការចែងផ្សេងពីនេះ។

82. លើសពីនេះ ធនាគារ ABBank មិនបានផ្តល់ថវិកាបន្ថែមទៀតដល់ក្រុមហ៊ុន EVNI ទេ ចាប់តាំងពីចុះហត្ថលេខាលើការវិនិយោគភាគហ៊ុនជាមួយ IFC ក្នុងខែធ្នូ ឆ្នាំ 2010។ ធនាគារ ABBank បានបញ្ជាក់ថា គ្មានមូលនិធិ IFC ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគរបស់ធនាគារ ABBank នៅក្នុងក្រុមហ៊ុន EVNI ឬការវិនិយោគរបស់ក្រុមហ៊ុន EVNI នៅក្នុងគម្រោង LS2 នោះទេ។

**<u>ការចូលរួមជាមួយ CAO</u>**

83. មុនពេលដាក់ស្នើរបាយការណ៍នេះ ថ្នាក់គ្រប់គ្រងបានចូលរួមជាប្រចាំជាមួយ CAO លើការឆ្លើយតបដែលបានស្នើឡើងរបស់ IFC ចំពោះអនុសាសន៍ជាប្រព័ន្ធរបស់ CAO។ IFC បានឆ្លើយសំណួរលើសកម្មភាព MAP ដែលបានស្នើឡើង ហើយបានកែសម្រួលសំណើរបស់ខ្លួនទៅតាមនោះ។

## VI. ផែនការសកម្មភាពគ្រប់គ្រង (MAP)

84. សកម្មភាព MAP ដែលបង្ហាញក្នុងឧបសម្ព័ន្ធ ក ឆ្លុះបញ្ចាំងពីសកម្មភាព និងដែនកំណត់ដែលបានពិពណ៌នានៅក្នុងផ្នែកខាងលើ។ វាបង្ហាញនូវសកម្មភាពជាប្រព័ន្ធចំនួនពីរដើម្បីឆ្លើយតបទៅនឹងអនុសាសន៍កម្រិតស្ថាប័នរបស់ CAO។

85. សកម្មភាពដែលបានបង្ហាញនៅក្នុងសកម្មភាព MAP ត្រូវបានពិគ្រោះយោបល់ជាមួយ CAO រួចហើយ។

86. IFC នឹងបង្កើតសន្លឹកណែនាំផ្ទៃក្នុងរបស់ IFC សម្រាប់ទាំងបុគ្គលិកផ្នែកវិនិយោគ និងបុគ្គលិក E&S ដោយផ្តល់ការណែនាំអំពីការវាយតម្លៃតម្រូវការសមត្ថភាពរបស់អតិថិជន FI រួមទាំងវិធីសាស្ត្រសម្រាប់ប៉ាន់ប្រមាណថ្លៃចំណាយពាក់ព័ន្ធទាក់ទងនឹងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព និងការអនុវត្ត ESMS។

87. បន្ទាប់ពីការធ្វើបច្ចុប្បន្នភាពលើនីតិវិធី ESRP ដើម្បីឆ្លុះបញ្ចាំងពីការរៀបចំផ្នែកស្ថាប័នរួចមក IFC នឹងពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍ណែនាំពាក់ព័ន្ធនានា ដែលផ្តល់ជូនសម្រាប់ការវិនិយោគតាមរយៈអន្តរការីហិរញ្ញវត្ថុ។ ការធ្វើបច្ចុប្បន្នភាពនេះនឹងផ្តល់នូវគោលការណ៍ណែនាំសម្រាប់បុគ្គលិកផ្នែកវិនិយោគ និងបុគ្គលិក E&S អំពីការបង្កើតវិធានការសមស្របសម្រាប់ប្រតិបត្តិការផ្សេងៗគ្នា ព្រមទាំងពង្រឹងការប្រើប្រាស់ឥទ្ធិពលនៅក្នុងគម្រោង FI ប្រភេទផ្សេងៗ។ នេះក៏នឹងរួមបញ្ចូលផងដែរនូវគោលការណ៍ណែនាំជាក់លាក់ស្តីពីការផ្សារភ្ជាប់ការប្តេជ្ញាចិត្តផ្នែក E&S នៅក្នុងផែនការ ESAP ទៅនឹងដំណាក់កាលសំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្តការបើកផ្តល់ប្រាក់កម្ចីលើកដំបូង និងការបើកផ្តល់ប្រាក់កម្ចីជាបន្តបន្ទាប់។

## VII. សេចក្តីសន្និដ្ឋាន

88. ថ្នាក់គ្រប់គ្រងសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមប្រកបដោយភាពស្ថាបនា និងការវាយតម្លៃយ៉ាងលម្អិតរបស់ក CAO នៅក្នុងរបាយការណ៍ស៊ើបអង្កេតអនុលោមភាពរបស់ខ្លួន។

89. ថ្នាក់គ្រប់គ្រងមិនយល់ស្របចំពោះលទ្ធផលរកឃើញរបស់ CAO ដែលថា
មានផលប៉ះពាល់កើតឡើងដោយសារការមិនអនុលោមតាមក្របខ័ណ្ឌនិរន្តរភាព របស់ IFC
នោះទេ។
លក្ខខណ្ឌតម្រូវនៃក្របខ័ណ្ឌនិរន្តរភាពមិនត្រូវបានបម្រុងទុកសម្រាប់អនុវត្តតាមប្រកបដោយ
អានុភាពប្រតិសកម្មនោះទេ។ លើសពីនេះ គ្មានមូលនិធិ IFC
ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ហិរញ្ញប្បទានដល់ក្រុមហ៊ុន EVNI ឬគម្រោង LS2 ឡើយ។
អាស្រ័យហេតុនេះ ក្នុងករណីដែលមិនមានការខ្វះចន្លោះក្នុងការអនុលោមតាមគោលនយោបាយ
នោះវាគ្មានមូលដ្ឋានណាមួយដើម្បីបង្កើតឱ្យមាននូវការផ្សាភ្ជាប់ចាំបាច់រវាងការចោទប្រកាន់ថា
IFC មិនបានអនុលោមតាមគោលនយោបាយ និងផលប៉ះពាល់ណាមួយដល់អ្នកដាក់ពាក្យបណ្តឹ
ងនោះទេ ខណៈដែលគម្រោងរបស់ពួកគេត្រូវបានចាប់ផ្តើមឡើងមុនពេលមានការវិនិយោគពី
IFC ហើយក៏មិនបានប្រើប្រាស់ប្រាក់ចំណូលណាមួយរបស់ IFC ដែរ។ ហេតុដូច្នេះ IFC
មិនអាចផ្តល់ជូននូវសកម្មភាព MAP ណាមួយដែលទាក់ទងនឹងគម្រោង LS2 បានទេ។

90. ថ្នាក់គ្រប់គ្រងសូមវាយតម្លៃខ្ពស់ចំពោះអនុសាសន៍កម្រិតស្ថាប័នរបស់ CAO
ដើម្បីពង្រឹងបន្ថែមទៀតនូវការអនុវត្តរបស់ IFC ក្នុងការគ្រប់គ្រងហានិភ័យ E&S
សម្រាប់ការវិនិយោគ FI។ អនុសាសន៍ទាំងនេះគឺស្របគ្នាជាមួយ
និងឆ្លុះបញ្ចាំងពីការកែលម្អនានា ដែល IFC
បានអនុវត្តរួចមកហើយចាប់តាំងពីការវិនិយោគក្នុងឆ្នាំ 2010។ IFC
ស្នើឡើងនូវសកម្មភាពជាក់លាក់ចំនួនពីរនៅក្នុងសកម្មភាព MAP
ដើម្បីពង្រឹងបន្ថែមទៀតនូវការណែនាំសម្រាប់បុគ្គលិក និងអតិថិជនរបស់ IFC
លើការគ្រប់គ្រងហានិភ័យ E&S ក្នុងការវិនិយោគ FI។

## ឧបសម្ព័ន្ធ ក៖ ផែនការសកម្មភាពគ្រប់គ្រង (MAP)

តារាងខាងក្រោមបង្ហាញនូវសកម្មភាព MAP ដែលបានស្នើឡើងដោយ IFC ដើម្បីឆ្លើយតបទៅនឹងអនុសាសន៍ជាប្រព័ន្ធដែល IFC អាចដោះស្រាយបាន។

| អនុសាសន៍/សកម្មភាពកម្រិតប្រព័ន្ធ | | |
|---|---|---|
| **អនុសាសន៍របស់ CAO** | **ចំណាត់ការ/សកម្មភាព** | **លទ្ធផលសម្រេចបាន** |
| **អនុសាសន៍ទី 1៖** ពង្រឹងសមត្ថភាព និងនីតិវិធី E&S សម្រាប់ការវិនិយោគ FI ដើម្បីធានាឱ្យបាននូវការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីហានិភ័យ E&S និងសមត្ថភាពផ្នែក E&S របស់អតិថិជនក្នុងអំឡុងពេលពិនិត្យពិច័យដោយហ្មត់ចត់ និងការតាមដានត្រួតពិនិត្យឱ្យបានត្រឹមត្រូវលើការសន្យា E&S ទាំងអស់ក្នុងអំឡុងពេលត្រួតពិនិត្យ។ សមត្ថភាពគួរតែត្រូវបានអភិវឌ្ឍដើម្បីធានាថា IFC មានបុគ្គលិកជំនាញក្នុងការគ្រប់គ្រងហានិភ័យ E&S របស់ FI ជាមួយនឹងការបណ្តុះបណ្តាលចំណេះដឹង និងបទពិសោធពាក់ព័ន្ធដើម្បីពិនិត្យ និងតាមដានការវិនិយោគ FI។ | ចាប់តាំងពីឆ្នាំ 2010 មក IFC បានអនុវត្តកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពយ៉ាងសំខាន់ ដើម្បីបង្កើនការត្រួតពិនិត្យយ៉ាងហ្មត់ចត់លើការវិនិយោគ FI ការត្រួតពិនិត្យ និងការត្រួតពិនិត្យលើការប្តេជ្ញាចិត្ត E&S។ ចំនួនអ្នកឯកទេស E&S ដែលគ្របដណ្តប់លើការវិនិយោគ FI បានកើនឡើងពី 5 នាក់ដល់ប្រហែល 30 នាក់ រួមទាំងអ្នកជំនាញឈានមុខគេក្នុងឧស្សាហកម្ម FI ក្នុងតំបន់ចំនួន 9 នាក់។ នៅក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក ចំនួនអ្នកឯកទេស E&S ដែលផ្តោតលើប្រតិបត្តិការ FI បានកើនឡើងពីអ្នកប្រឹក្សារយៈពេលខ្លីពីរនាក់ ដល់បុគ្គលិកធម្មតាបួននាក់ ដែលទទួលបានការគាំទ្រពីអ្នកប្រឹក្សារយៈពេលខ្លីបន្ថែម។ នៅឆ្នាំ 2013, IFC បានពង្រីកកិច្ចខិតខំប្រឹងប្រែងត្រួតពិនិត្យ FI របស់ខ្លួន។ បន្ថែមពីលើការត្រួតពិនិត្យប្រចាំឆ្នាំរបស់អតិថិជន FI-1 ទាំងអស់ ឥឡូវនេះ IFC ត្រួតពិនិត្យជារៀងរាល់ឆ្នាំ អតិថិជន FI-2 ទាំងអស់ស្ថិតនៅក្រោមការអនុវត្ត PS ដោយអនុគម្រោងរបស់ពួកគេ។ ការគាំទ្រកាន់តែច្រើនសម្រាប់អតិថិជនដែលមានហានិភ័យខ្ពស់តម្រូវឱ្យមានការផ្លាស់ប្តូរជនជានឡើងវិញ។ ក្នុងឆ្នាំ 2018, IFC បានកែសម្រួលឡើងវិញនូវវិធីសាស្ត្រវាយតម្លៃហានិភ័យ E&S ដើម្បីសម្រួលដល់ដំណើរការវាយតម្លៃ និងតាមដានត្រួតពិនិត្យសម្រាប់អតិថិជន FI ដែលមានហានិភ័យទាប និងមធ្យមកម្រិតទាប ហើយតាមរយៈនេះគឺអនុញ្ញាត | វគ្គបណ្តុះបណ្តាលដែលបានបញ្ចប់៖ វគ្គថ្មីៗពាក់ព័ន្ធមួយចំនួនដែលផ្តោតលើ FI ទៅកាន់អ្នកឯកទេស E&S ដែលបានធ្វើឡើងនៅទីក្រុងបាងកកក្នុងឆ្នាំ 2024 ទីក្រុងអ៊ីស្តង់ប៊ុល ទីក្រុងវីយែន ទីក្រុងបូហ្គោតា និងទីក្រុងគែរក្នុងឆ្នាំ 2025 និង 2026។ វគ្គណែនាំដែលបានបញ្ចប់៖ សម្រាប់វគ្គណែនាំថ្មីៗពាក់ព័ន្ធមួយចំនួន សូមមើលការណែនាំសកម្មភាព MAP របស់ IFC ស្តីពីគម្រោង Bridge 4 របស់ប្រទេសកេនយ៉ា ទៅកាន់នាយកតែងតាំងដោយ IFC។ |

| | | |
|---|---|---|
| | ឱ្យស្ថាប័នអាចបែងចែកធនធានបន្ថែមទៀតទៅលើអតិថិជន FI ដែលមានហានិភ័យខ្ពស់ និងមធ្យមកម្រិតខ្ពស់។ ចាប់តាំងពីឆ្នាំ 2019 មក បញ្ជីហានិភ័យខ្ពស់របស់ FI ត្រូវបានបង្កើតឡើង និងតាមដានត្រួតពិនិត្យដោយមន្ត្រីទទួលបន្ទុកហានិភ័យ E&S របស់ FI នាំមុខគេ ដែលពួកគាត់ក៏បានអមដំណើរជាមួយអ្នកឯកទេសផ្នែក E&S ប្រចាំតំបន់ក្នុងការចុះទៅពិនិត្យតាមដានដោយផ្ទាល់ផងដែរ។<br>បុគ្គលិក E&S ទទួលបានការបណ្ដុះបណ្ដាលជាប្រចាំលើ PSs និងនីតិវិធីរបស់ IFC រួមទាំងកម្មវិធីណែនាំបុគ្គលិកចូលបម្រើការងារ ក៏ដូចជាការកសាងសមត្ថភាពក្នុងតំបន់។<br>វគ្គបណ្ដុះបណ្ដាលពាក់ព័ន្ធថ្មីៗមួយចំនួនដែលផ្ដោតលើ FI សម្រាប់អ្នកឯកទេស E&S ត្រូវបានធ្វើឡើងជាផ្នែកមួយនៃព្រឹត្តិការណ៍បណ្ដុះបណ្ដាលទូទាំងក្រសួង និងសិក្ខាសាលា FI រួមទាំងសិក្ខាសាលា FI រយៈពេលមួយសប្ដាហ៍នៅទីក្រុងបាងកកក្នុងឆ្នាំ 2024 សិក្ខាសាលា FI រយៈពេលបីថ្ងៃនៅទីក្រុងអ៊ីស្តង់ប៊ុលក្នុងឆ្នាំ 2025 វគ្គបណ្ដុះបណ្ដាល FI នៅក្នុងទីក្រុងវីយែន បូហ្គោតា និងគែរក្នុងឆ្នាំ 2025 និង 2026។ | |

| | | |
|---|---|---|
| | ថ្នាក់គ្រប់គ្រងកត់សម្គាល់ថា MAPs របស់ IFC ដែលឆ្លើយតបទៅនឹងការស៊ើបអង្កេត CAO ផ្សេងទៀតក៏រួមបញ្ចូលទាំងការបណ្តុះបណ្តាលបុគ្គលិក និងអតិថិជនពាក់ព័ន្ធ និងគំនិតផ្តួចផ្តើមកសាងសមត្ថភាពផងដែរ។ នៅក្នុងផែនការ MAP របស់ខ្លួនជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតលើគម្រោង Bridge 4 ក្នុងប្រទេសកេនយ៉ា ស្ថាប័ន IFC បានបង្កើតនូវសេចក្តីណែនាំសម្រាប់នាយកតែងតាំងដោយ IFC។ ចាប់តាំងពីខែតុលា ឆ្នាំ 2023 មក នាយកតែងតាំងដោយ IFC ថ្មីៗទទួលបាននូវការណែនាំអំពីការពិនិត្យមើលឡើងវិញនូវហានិភ័យ E&S។ វគ្គបណ្តុះបណ្តាលគោលដៅពីរលើកដំបូងស្តីពីអភិបាលកិច្ចហានិភ័យនៃអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ (GBV Risk Governance) សម្រាប់នាយកតែងតាំងដោយ IFC បានប្រព្រឹត្តទៅក្នុងខែមករា និងខែមិថុនា ឆ្នាំ 2024។ វគ្គបណ្តុះបណ្តាលទាំងនេះនឹងត្រូវបន្តអនុវត្តដោយមានការរំលឹកឡើងវិញជាប្រចាំឆ្នាំ។ | |

| | | |
|---|---|---|
| **អនុសាសន៍ទី 2៖** បង្កើត និងផ្សព្វផ្សាយក្នុងចំណោមបុគ្គលិក E&S នូវការណែនាំលម្អិតស្តីពីលក្ខខណ្ឌតម្រូវនៃការត្រួតពិនិត្យ E&S សម្រាប់ការវិនិយោគគោលបំណងទូទៅរបស់អតិថិជន FI ដូចជាការវិនិយោគភាគហ៊ុនជាដើម។ ក្នុងចំណោមផ្សេងទៀត ការណែនាំនេះគួរតែរួមបញ្ចូលការណែនាំជាក់លាក់ស្តីពី៖<br>ក.<br>របៀបពិនិត្យឡើងវិញនូវគំរូតំណាងនៃការវិនិយោគ ប្រតិបត្តិការ ផលិតផល និងវិស័យដែលមានហានិភ័យខ្ពស់ នៅក្នុងផលប័ត្ររបស់ FI ក្នុងអំឡុងពេលធ្វើការស៊ើបអង្កេតយ៉ាងហ្មត់ចត់ ដើម្បីកំណត់សមត្ថភាព E&S ដែលត្រូវការសម្រាប់អតិថិជន និងដើម្បីកំណត់ថ្លៃដើមនៃសកម្មភាពបរិស្ថាន និងសង្គម (ESAP) របស់គម្រោង និងការចំណាយប្រចាំឆ្នាំជាមធ្យមនៃការអនុវត្ត ESMS របស់អតិថិជន។<br>របៀបវាយតម្លៃបុគ្គលិក E&S ចាំបាច់ជាអប្បបរមាដែលត្រូវការសម្រាប់ FI ដោយផ្អែកលើហានិភ័យ E&S នៃផលប័ត្រ និងការផ្លាស់ប្តូរបុគ្គលិក និងសមត្ថភាពរបស់ FI ក្នុងការទទួលយកបុគ្គលិក E&S ថ្មី។ ក្នុងករណីនេះ និងករណីផ្សេងទៀត CAO បានសង្កេតឃើញថា ចំណុចខ្វះខាតនៅក្នុងសមត្ថភាព E&S របស់អតិថិជន ជារឿយៗជាបញ្ហាដែលកើតឡើងម្តងហើយម្តងទៀត។ IFC | ចាប់តាំងពីការវិនិយោគរបស់ IFC ក្នុងឆ្នាំ 2010 មក ការធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌនិរន្តរភាពរបស់ IFC ក្នុងឆ្នាំ 2012 បានបញ្ជាក់ពីលក្ខខណ្ឌតម្រូវ E&S ជាច្រើនលើការពិនិត្យពិច័យ និងការត្រួតពិនិត្យសម្រាប់ទាំងបុគ្គលិក និងអតិថិជនរបស់ IFC។ IFC ក៏បានបង្កើតកំណត់ចំណាំបកស្រាយ FI ក្នុងឆ្នាំ 2012 ដែលត្រូវបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ 2018 ហើយបន្ទាប់មកត្រូវបានជំនួសដោយកំណត់ចំណាំណែនាំថ្មីមួយស្តីពី FIs ក្នុងឆ្នាំ 2023 ផងដែរ។ កំណត់ចំណាំណែនាំនេះកំណត់ដើម្បី (i) បញ្ជាក់បន្ថែមអំពីអ្វីដែលត្រូវបានចាត់ទុកថាជាប្រតិបត្តិការហានិភ័យ E&S ខ្ពស់ជាង (ii) រួមបញ្ចូលនិយមន័យនៃប្រតិបត្តិការហានិភ័យ E&S ខ្ពស់ជាងនៅក្នុងលក្ខណៈវិនិច្ឆ័យដែលប្រើដោយ FIs ដើម្បីកំណត់ប្រតិបត្តិការប្រភេទទាំងនេះ (iii) បញ្ជាក់ពីកាលៈទេសៈដែលតម្រូវឱ្យមានការយកចិត្តទុកដាក់លើ FI កាន់តែប្រសើរឡើង (iv) កំណត់ការទទួលខុសត្រូវ E&S របស់អតិថិជន FI ទាក់ទងនឹងអនុគម្រោង និងអនុគម្រោងរង (v) កំណត់ការប្តេជ្ញាចិត្តក្នុងការបង្ហាញព័ត៌មានអនុគម្រោង និង (vi) បង្កើនភាពច្បាស់លាស់លើវិសាលភាពនៃការអនុវត្តលក្ខខណ្ឌតម្រូវ E&S រួមទាំង PSs របស់ IFC ដោយអតិថិជន FI សម្រាប់ប្រតិបត្តិការហានិភ័យ E&Sខ្ពស់ជាង។<br>ក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ IFC បានបង្កើត និងពង្រឹង ESRP របស់ខ្លួន ដែលភ្ជាប់មកជាមួយនឹងសន្លឹកណែនាំដែលផ្តល់ការណែនាំសម្រាប់បុគ្គលិក IFC ស្តីពី ESDD និងការត្រួតពិនិត្យសម្រាប់ការវិនិយោគ FI។ បច្ចុប្បន្នភាពពាក់ព័ន្ធរួមមាន៖ (i) ការពង្រឹងសូចនាករការអនុវត្តការត្រួតពិនិត្យសំខាន់ៗ (ii) ភាពច្បាស់លាស់លើនីតិវិធីវាយតម្លៃហានិភ័យសម្រាប់ប្រតិបត្តិការ FI (iii) ការណែនាំសម្រាប់អ្នកឯកទេសអំពីពេលដែលតម្រូវឱ្យមានការពង្រឹងការត្រួតពិនិត្យ ESDD របស់ FI (iv) លក្ខខណ្ឌតម្រូវដើម្បីផ្ទៀងផ្ទាត់ធនធានអតិថិជនសម្រាប់ការអនុវត្ត ESMS ជាផ្នែកមួយនៃ ESAP (v) | វគ្គណែនាំដែលបានបញ្ចប់។<br>វគ្គណែនាំថ្មីៗពាក់ព័ន្ធមួយចំនួនរួមមាន៖<br>ក្របខ័ណ្ឌនិរន្តរភាពឆ្នាំ 2012<br>កំណត់ចំណាំបកស្រាយ FI ឆ្នាំ 2012 (ជំនួស)<br>កំណត់ចំណាំបកស្រាយ FI ឆ្នាំ 2018 (ជំនួស)<br>កំណត់សម្គាល់ណែនាំឆ្នាំ 2023 ស្តីពីអន្តរការីហិរញ្ញវត្ថុ<br>2024, IFC ESRP<br>សកម្មភាព MAP ឆ្នាំ 2024 របស់ IFC ស្តីពីគម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង<br>ការណែនាំអំពីការផ្តល់ធនធាន និងការគណនាថ្លៃចំណាយលើ ESAP<br>សន្លឹកណែនាំ ឆ្នាំ 2025 ស្តីពីការត្រួតពិនិត្យ FI<br>សន្លឹកណែនាំ ឆ្នាំ 2025 ស្តីពីលក្ខវិនិច្ឆ័យនៃការពិនិត្យគំរូផលប័ត្រ FI |

| | | |
|---|---|---|
| គួរតែបង្កើតឧបករណ៍ និងប៉ារ៉ាម៉ែត្រសម្រាប់បុគ្គលិក E&S របស់ខ្លួន | ការពង្រឹងការផ្ទៀងផ្ទាត់ការអនុវត្ត ESMS ជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃ | |

| | | |
|---|---|---|
| ដើម្បីវាយតម្លៃលើតម្រូវការបុគ្គលិក E&S របស់អតិថិជនធៀបនឹងផលប័ត្រហានិភ័យ E&S របស់អតិថិជននោះ។ | ការបើកផ្តល់ប្រាក់កម្ចី និង (vi) ការណែនាំដែលប្រសើរឡើងសម្រាប់អ្នកឯកទេសលើឧបករណ៍វាយតម្លៃហានិភ័យ និងការអនុវត្តរបស់ពួកគេ។ ការធ្វើបច្ចុប្បន្នភាព ESRP ក្នុងខែធ្នូ ឆ្នាំ 2024 ដែលបានឆ្លុះបញ្ចាំង ក្នុងចំណោមការផ្លាស់ប្តូរផ្សេងទៀត មេរៀនដែលបានរៀនពីករណី CAO ថ្មីៗ។<br>អ្នកឯកទេសនាំមុខគេផ្នែកបរិស្ថាន និងសង្គម (LESS) របស់ IFC ទទួលខុសត្រូវចំពោះគុណភាព និងសង្គតិភាពនៃផែនការ ESAP មុនពេលវាត្រូវបានដាក់ជូនសម្រាប់វាយតម្លៃ និងដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងវិនិយោគ។<br>អតិថិជនត្រូវបានស្នើសុំឱ្យរៀបចំការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់ការអនុវត្ត ESAP និងចែករំលែកការប៉ាន់ប្រមាណទាំងនេះជាមួយ IFC។ អ្នកឯកទេស LESS រួមជាមួយក្រុមវិនិយោគពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃការប៉ាន់ប្រមាណថ្លៃចំណាយរបស់អតិថិជនសម្រាប់ការអនុវត្តគម្រោង ESAP ហើយតាមតម្រូវការនឹងចូលរួមជាមួយអតិថិជន ប្រសិនបើមានការព្រួយបារម្ភអំពីសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់ធនធានដែលត្រូវការ ឬការយល់ដឹងរបស់ខ្លួនអំពីតម្រូវការបែបនេះ។<br>IFC បញ្ជាក់ថា សកម្មភាព MAP របស់ខ្លួនជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ CAO លើគម្រោង Lonmin ប្រទេសអាហ្វ្រិកខាងត្បូង រួមមានសកម្មភាពបង្កើតការណែនាំ និងពង្រឹងដំណើរការត្រួតពិនិត្យផ្ទៃក្នុង (i) ដើម្បីពិនិត្យមើលភាពគ្រប់គ្រាន់នៃការប៉ាន់ប្រមាណរបស់អតិថិជនលើធនធានសម្រាប់ការអនុវត្តផែនការ ESAP ដូចដែលបានតម្រូវនៅក្នុង PS1 (2012) កថាខណ្ឌទី 16 និង (ii)កត់ត្រាទុកនូវការពិនិត្យឡើងវិញនេះទុកជាផ្នែកមួយនៃឯកសារវាយតម្លៃ។ ជាលទ្ធផល ESRP និងការណែនាំដែលត្រូវគ្នាត្រូវបានធ្វើបច្ចុប្បន្នភាព។ | |

| | | |
|---|---|---|
| | ការបណ្តុះបណ្តាលត្រូវបានផ្តល់ជូនសម្រាប់បុគ្គលិកសំខាន់ៗផ្នែក E&S នៅថ្ងៃទី 12 ខែកុម្ភៈ ឆ្នាំ 2024 ដើម្បីចែករំលែកការណែនាំជាក់លាក់អំពីអ្វីដែលរំពឹងទុកពី LESS និងបានផ្សព្វផ្សាយការណែនាំនេះយ៉ាងទូលំទូលាយ។ ប្រព័ន្ធពិនិត្យ និងចងក្រងឯកសារ E&S នៃគម្រោងរបស់ IFC គឺ ESG360 រួមបញ្ចូលម៉ូឌុលស្តីពីការតាមដាន ESAP ដែលត្រូវបានធ្វើបច្ចុប្បន្នភាពដើម្បីបញ្ចូលការប៉ាន់ស្មានថ្លៃចំណាយ ESAP។ នៅឆ្នាំ 2025, IFC បានបង្កើតការណែនាំសម្រាប់បុគ្គលិក E&S អំពីរបៀបពិនិត្យមើលឡើងវិញនូវគំរូតំណាងនៃការវិនិយោគដែលមានហានិភ័យខ្ពស់នៅក្នុងប្រតិបត្តិការ FI។ CAO បានផ្តល់មតិកែលម្អ និងមតិចូលរួម។ | |
| | សន្លឹកកិច្ចការណែនាំរបស់ IFC ដែលផ្តល់ការណែនាំអំពីការវាយតម្លៃលើតម្រូវការសមត្ថភាពរបស់អតិថិជនជា FI រួមទាំងវិធីសាស្ត្រសម្រាប់ការប៉ាន់ប្រមាណថ្លៃដើមដែលពាក់ព័ន្ធនឹងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព និងការអនុវត្ត ESMS។ | សន្លឹកណែនាំផ្ទៃក្នុងរបស់ IFC ត្រូវបានផ្សព្វផ្សាយ និងដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកផ្នែក E&S និងបុគ្គលិកផ្នែកវិនិយោគ។ កាលវិភាគ: ត្រីមាសទី 2 ឆ្នាំសារពើពន្ធ 27 |

| | | |
|---|---|---|
| **អនុសាសន៍ទី 3៖** ធ្វើការពិនិត្យឡើងវិញនូវផលប័ត្រនៃការវិនិយោគ FI ភាគហ៊ុនសកម្មរបស់ IFC ចាប់តាំងពីឆ្នាំ 2006 ដែលរួមបញ្ចូលកាតព្វកិច្ចនៅក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់ (ESAP ឬកន្លែងផ្សេងទៀត) សម្រាប់អតិថិជនដើម្បីអនុវត្ត ESMS របស់ខ្លួនចំពោះ “ប្រាក់កម្ចីដែលមានស្រាប់ និងការវិនិយោគ” និងធានាថាមានការត្រួតពិនិត្យគ្រប់គ្រាន់លើការប្តេជ្ញាចិត្តតាមផ្លូវច្បាប់ត្រូវបានអនុវត្ត។ | ថ្នាក់គ្រប់គ្រងមិនយល់ស្របនឹងអនុសាសន៍របស់ CAO នេះទេ។ ដូចដែលបានរៀបរាប់ខាងលើ ទោះបីជាលក្ខខណ្ឌតម្រូវដែលមានក្នុងកិច្ចព្រមព្រៀងផ្លូវច្បាប់រវាង IFC និងធនាគារ ABBank ក្នុងឆ្នាំ 2010 មានវិសាលភាពទូលំទូលាយខុសឆ្គងក៏ដោយ ក៏ការពិនិត្យឡើងវិញរបស់ IFC ត្រូវបានដឹកនាំដោយគោលនយោបាយនិរន្តរភាព ដូច្នេះហើយមិនមានការមិនអនុលោមតាមគោលនយោបាយនិរន្តរភាពរបស់ IFC នោះទេ។ កិច្ចព្រមព្រៀងផ្លូវច្បាប់ត្រូវអានក្នុងក្របខ័ណ្ឌនៃគោលនយោបាយនិរន្តរភាព ហើយការបកស្រាយ និងការអនុវត្តរបស់ពួកគេមិនអាចផ្ទុយនឹងស្មារតី និងខ្លឹមសារនៃគោលនយោបាយដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលនោះទេ។<br>ដោយពិចារណាថាគោលនយោបាយនិរន្តរភាពឆ្នាំ 2006 និង 2012 មិនបានចែងអំពីការអនុវត្តលក្ខខណ្ឌតម្រូវ E&S របស់ IFC ប្រកបដោយអនុភាពប្រតិសកម្មចំពោះផលប័ត្រ FIs ដែលមានស្រាប់នោះទេ ក្នុងករណីដែលលក្ខខណ្ឌតម្រូវបែបនេះត្រូវបានតាក់តែងឡើងយ៉ាងទូលំទូលាយដោយច្រឡំ IFC មិន មិនបានអនុវត្ត ហើយនឹងមិនអនុវត្តបទប្បញ្ញត្តិបែបនេះទេ។<br>នៅក្នុងបរិបទនេះ IFC បានគូសបញ្ជាក់ថា គោលនយោបាយនិរន្តរភាពឆ្នាំ 2012 បញ្ជាក់ថា ក្នុងករណីដែល IFC ផ្តល់ការគាំទ្រផ្នែកភាគហ៊ុន ឬហិរញ្ញវត្ថុសម្រាប់គោលបំណងទូទៅ លក្ខខណ្ឌតម្រូវអនុវត្តចំពោះផលប័ត្ររបស់អន្តរការីហិរញ្ញវត្ថុដែល មានប្រភពមកពីពេលដែល IFC ក្លាយជាភាគទុនិក ឬវិនិយោគិន។<br>ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ IFC ក៏បានពិនិត្យមើលឡើងវិញ និងបានធ្វើបច្ចុប្បន្នភាពគំរូកិច្ចព្រមព្រៀងផ្លូវច្បាប់របស់ខ្លួន ព្រមទាំងបានកែសម្រួលពួកវា ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវនៃគោលនយោបាយដែលមានចែងក្នុងផ្នែកទី 37 នៃគោលនយោបាយនិរន្តរភាពឆ្នាំ 2012។ | វត្ថុណែនាំដែលបានបញ្ចប់។<br>វត្ថុណែនាំពាក់ព័ន្ធដែលបានបញ្ចប់មួយចំនួនរួមមាន៖<br>គោលនយោបាយនិរន្តរភាពឆ្នាំ 2012<br>កំណត់សម្គាល់ណែនាំឆ្នាំ 2023 ស្តីពីអន្តរការីហិរញ្ញវត្ថុ<br>2024 IFC ESRP<br>សកម្មភាព MAP របស់ IFC ឆ្នាំ 2022 ស្តីពីធនាគារ RCBC ប្រទេសហ្វីលីពីន<br>កំណត់សម្គាល់ការអនុវត្តល្អស្តីពីកិច្ចព្រមព្រៀងផ្លូវច្បាប់ E&S |

| | | |
|---|---|---|
| | លើសពីនេះ ជាផ្នែកមួយនៃសកម្មភាព MAP របស់ IFC ជាការឆ្លើយតបទៅនឹងការស៊ើបអង្កេតរបស់ CAO លើធនាគារ RCBC ប្រទេសហ្វីលីពីន IFC បានបង្កើត និងផ្សព្វផ្សាយនូវកំណត់សម្គាល់ការអនុវត្តល្អសម្រាប់អតិថិជន និងបុគ្គលិកស្តីពីគំរូកិច្ចព្រមព្រៀងផ្លូវច្បាប់ E&S ក្នុងការវិនិយោគ FI។ សន្លឹកណែនាំសម្រាប់ FI ត្រូវបានបោះពុម្ពផ្សាយនៅលើគេហទំព័ររបស់ IFC ក្នុងខែមីនា ឆ្នាំ 2023 និងអាចចូលមើលជាសាធារណៈបាន។ | |
| **អនុសាសន៍ទី 4៖** ធ្វើបច្ចុប្បន្នភាពនីតិវិធី ESRP របស់ខ្លួនដើម្បីផ្តល់ការណែនាំឱ្យកាន់តែច្បាស់លាស់ដល់បុគ្គលិក E&S អំពីរបៀបរៀបចំរចនាសម្ព័ន្ធវិនិយោគ ដើម្បីប្រើប្រាស់ឥទ្ធិពលរបស់ IFC ឱ្យបានល្អបំផុតក្នុងអំឡុងពេលនៃដំណើរការវិនិយោគ សំដៅធានាឱ្យបាននូវការអនុលោមតាមលក្ខខណ្ឌតម្រូវ E&S របស់អតិថិជន។ ដូចដែលបាន | ESRP របស់ IFC គឺជាឯកសាររស់មួយដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររចនាសម្ព័ន្ធស្ថាប័ន និងមេរៀនដែលបានរៀនពីប្រតិបត្តិការរបស់ IFC។ បច្ចុប្បន្នភាពនៃនីតិវិធី ESRP ក្នុងខែធ្នូ ឆ្នាំ 2024 បានដាក់បញ្ចូលនូវអនុសាសន៍ជាប្រព័ន្ធស្រដៀងគ្នាដែលទទួលបានពីសំណុំរឿងផ្សេងៗទៀតរបស់ CAO។ IFC បានធ្វើបច្ចុប្បន្នភាព FI ទៅលើគម្រោង ESRP និងសន្លឹកណែនាំដែលត្រូវគ្នា ដែលរួមមាន៖ (i) ការពង្រឹងសូចនាករការអនុវត្ត | នីតិវិធីដែលបានបញ្ចប់រួចរាល់៖ វគ្គណែនាំថ្មីៗពាក់ព័ន្ធរួមមាន៖ ESRP ឆ្នាំ 2024<br>សន្លឹកណែនាំ ESAP ឆ្នាំ 2024 |

| | | |
|---|---|---|
| ផ្តល់អនុសាសន៍នៅក្នុងករណីមុនៗ ការងារនេះគួរតែរួមបញ្ចូលនូវការណែនាំច្បាស់លាស់អំពីតម្រូវការក្នុងការផ្សារភ្ជាប់ការប្តេជ្ញាចិត្តផ្នែក E&S នៅក្នុង ESAP ឬកិច្ចព្រមព្រៀងផ្លូវច្បាប់ទៅនឹងដំណាក់កាលសំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការបើកផ្តល់ប្រាក់កម្ចីលើកដំបូង និងការ បើកផ្តល់ប្រាក់កម្ចីជាបន្តបន្ទាប់ ដើម្បីធានាថា IFC មានឥទ្ធិពលគ្រប់គ្រាន់ក្នុងការតម្រូវឱ្យមានការបំពេញកិច្ចការទាំងនោះឱ្យបានជោគជ័យ។ | ការត្រួតពិនិត្យសំខាន់ៗ (ii) ភាពច្បាស់លាស់លើនីតិវិធីវាយតម្លៃហានិភ័យសម្រាប់ប្រតិបត្តិការ FI (iii) ការណែនាំសម្រាប់អ្នកឯកទេសអំពីពេលដែលតម្រូវឱ្យមានការពង្រឹងការត្រួតពិនិត្យ ESDD របស់ FI (iv) លក្ខខណ្ឌតម្រូវដើម្បីផ្ទៀងផ្ទាត់ធនធានអតិថិជនសម្រាប់ការអនុវត្ត ESMS ជាផ្នែកមួយនៃ ESAP (v) ការពង្រឹងការផ្ទៀងផ្ទាត់ការអនុវត្ត ESMS ជាផ្នែកមួយនៃលក្ខខណ្ឌតម្រូវនៃការបើកផ្តល់ប្រាក់កម្ចី និង (vi) ការណែនាំដែលប្រសើរឡើងសម្រាប់អ្នកឯកទេសលើឧបករណ៍វាយតម្លៃហានិភ័យ និងការអនុវត្តរបស់ពួកគេ។ ស្ថាប័ន IFC ក៏បានបង្កើតនូវឧបករណ៍វិនិច្ឆ័យប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS Diagnostics Tool) និងបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈ ដើម្បីបង្កើនភាពស៊ីចង្វាក់គ្នាក្នុងការរៀបចំ និងការអនុវត្តប្រព័ន្ធ ESMSs របស់អតិថិជន FI។ | |
| | បន្ទាប់ពីការធ្វើបច្ចុប្បន្នភាពលើនីតិវិធី ESRP រួចមក IFC នឹងពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពលើគោលការណ៍ណែនាំផ្ទៃក្នុងពាក់ព័ន្ធនានា ដែលផ្តល់ជូនសម្រាប់ការវិនិយោគតាមរយៈអន្តរការីហិរញ្ញវត្ថុ។ ការធ្វើបច្ចុប្បន្នភាពនេះនឹងផ្តល់នូវគោលការណ៍ណែនាំសម្រាប់ LESSs និង IOs អំពីការបង្កើតវិធានការសមស្របសម្រាប់ប្រតិបត្តិការផ្សេងៗគ្នា ព្រមទាំងពង្រឹងការប្រើប្រាស់ឥទ្ធិពលនៅក្នុងគម្រោង FI ប្រភេទផ្សេងៗ។ នេះក៏នឹងរួមបញ្ចូលផងដែរនូវគោលការណ៍ណែនាំជាក់លាក់ស្តីពីការផ្សារភ្ជាប់ការប្តេជ្ញាចិត្តផ្នែក E&S នៅក្នុងផែនការ ESAP ទៅនឹងដំណាក់កាលសំខាន់ៗនៃការវិនិយោគ ដូចជាការប្តេជ្ញាចិត្ត ការបើកផ្តល់ប្រាក់កម្ចីលើកដំបូង និងការបើកផ្តល់ប្រាក់កម្ចីជាបន្តបន្ទាប់។ | ការណែនាំផ្ទៃក្នុងរបស់ IFC ត្រូវបានផ្សព្វផ្សាយ និងដាក់បញ្ចូលទៅក្នុងវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិកផ្នែក E&S និងបុគ្គលិកផ្នែកវិនិយោគ។ កាលវិភាគៈ ត្រីមាសទី 2 ឆ្នាំសារពើពន្ធ 27 |

**សេចក្ដីប្រកាសបដិសេធ**

របាយការណ៍គ្រប់គ្រងរបស់ IFC ត្រូវបានផ្ដល់ជូនជាការឆ្លើយតបទៅនឹងរបាយការណ៍ស៊ើបអង្កេតរបស់ការិយាល័យផ្ដល់ប្រឹក្សាផ្នែកអនុលោមភាព (CAO) ពាក់ព័ន្ធនឹងបណ្ដឹងតវ៉ាអំពីការចោទប្រកាន់ថាមានការមិនអនុលោមតាមបទដ្ឋានប្រតិបត្តិរបស់ IFC ស្ដីពីនិរន្តរភាពបរិស្ថាន និងសង្គម នៅក្នុងគម្រោងដែលគាំទ្រដោយហិរញ្ញប្បទាន ឬការវិនិយោគរបស់ IFC។

CAO គ្រប់គ្រងយន្តការគណនេយ្យភាពរបស់ IFC ក្នុងគោលបំណងដោះស្រាយបណ្ដឹងតវ៉ាដោយបុគ្គលដែលរងផលប៉ះពាល់ដោយគម្រោងគាំទ្រដោយ IFC។ ដូចដែលបានកត់សម្គាល់ក្នុងកថាខណ្ឌទី 9 នៃគោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ (CAO) របស់ IFC/MIGA, CAO មិនមានសមត្ថកិច្ចពាក់ព័ន្ធនឹងដំណើរការប្រព័ន្ធតុលាការឡើយ។ CAO មិនមែនជាយន្តការអនុវត្តច្បាប់ ឬតុលាការទេ ហើយ CAO ក៏មិនមែនជាស្ថាប័នជំនួសឱ្យតុលាការ ឬដំណើរការនិយ័តកម្មដែរ ការវិភាគ សេចក្ដីសន្និដ្ឋាន និងរបាយការណ៍របស់ CAO មិនត្រូវបានបម្រុងទុក ឬរៀបចំឡើងដើម្បីប្រើប្រាស់ក្នុងដំណើរការនីតិវិធីតុលាការ ឬនិយ័តកម្ម ឬសម្រាប់គោលបំណងកំណត់កំហុសផ្លូវច្បាប់ ឬការទទួលខុសត្រូវឡើយ។

គ្មានខ្លឹមសារណាមួយដែលមាននៅក្នុងរបាយការណ៍ស៊ើបអង្កេតរបស់ CAO ឬនៅក្នុងរបាយការណ៍គ្រប់គ្រងរបស់ IFC (1) បង្កើតកាតព្វកិច្ចផ្លូវច្បាប់ណាមួយ (2) អះអាង ឬបោះបង់ជំហរផ្លូវច្បាប់ណាមួយ (3) កំណត់ការទទួលខុសត្រូវតាមផ្លូវច្បាប់ ការទទួលខុសត្រូវលើសំណង ឬអំពើខុសឆ្គងណាមួយ (4) បង្កើតឱ្យមានការទទួលស្គាល់ ឬការយល់ព្រមលើកាលៈទេសៈជាក់ស្ដែងណាមួយ ឬភស្តុតាងនៃកំហុស ឬអំពើខុសឆ្គងណាមួយ ឬ (5) បង្កើតឱ្យមានការបោះបង់សិទ្ធិឯកសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយរបស់ IFC ក្រោមប្រការនៃកិច្ចព្រមព្រៀង អនុសញ្ញាអន្តរជាតិ ឬច្បាប់ជាធរមានផ្សេងទៀតរបស់ខ្លួនឡើយ។ IFC រក្សាសិទ្ធិគ្រប់យ៉ាងយ៉ាងច្បាស់លាស់។

ទោះបីជាមានការខិតខំប្រឹងប្រែងសមស្របដើម្បីកំណត់ថាព័ត៌មានដែលមាននៅក្នុងរបាយការណ៍ទាំងនេះមានភាពត្រឹមត្រូវក៏ដោយ ក៏មិនមានការធានា ឬការអះអាងណាមួយចំពោះភាពត្រឹមត្រូវ ឬភាពពេញលេញនៃព័ត៌មានបែបនេះដែរ។ ក្នុងការរៀបចំរបាយការណ៍គ្រប់គ្រងនេះ IFC មិនមានបំណងបង្កើត យល់ព្រម ឬទទួលយកកាតព្វកិច្ច ឬករណីកិច្ចផ្លូវច្បាប់ណាមួយ ឬកំណត់អត្តសញ្ញាណ ឬទទួលយកការចោទប្រកាន់ណាមួយអំពីការរំលោភលើកាតព្វកិច្ច ឬករណីកិច្ចផ្លូវច្បាប់នោះឡើយ។ គ្មានផ្នែកណាមួយនៃរបាយការណ៍ស៊ើបអង្កេតរបស់ក CAO ឬរបាយការណ៍គ្រប់គ្រងរបស់ IFC អាចត្រូវបានប្រើប្រាស់ ឬយោងទៅនៅក្នុងដំណើរការប្រព័ន្ធតុលាការ មជ្ឈត្តការ និយ័តកម្ម ឬដំណើរការផ្សេងទៀត ដោយគ្មានការយល់ព្រមច្បាស់លាស់ជាលាយលក្ខណ៍អក្សរពី IFC ឡើយ។